00981701

E301/9/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 04 / 2014
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada


សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឧត្តរ** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

00981702

E301/9/1

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសារណារបស់ភាគីស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២ និង សំណើរបស់ពួកគេដែលស្នើសុំឱ្យសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការពាក់ព័ន្ធនឹងបទចោទនានាដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ។ សារណាខាងលើត្រូវបានដាក់នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ តាមសំណើរបស់អង្គជំនុំជម្រះ[1]។ សវនាការផ្ទាល់មាត់លើបញ្ហានេះត្រូវបានធ្វើនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤[2]។

## ២. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២ ទៅជាសំណុំរឿងពីរ ឬច្រើន។ អង្គជំនុំជម្រះបានសម្រេចថា ផ្នែកទីមួយនៃសំណុំរឿង ០០២ ដែលក្រោយមកត្រូវបានហៅថា "សំណុំរឿង ០០២/០១" គួររួមមាន៖

ក) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។

ខ) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ

[1] ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ, ឯកសារ E301/5 ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣; សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និង ការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ព័ន្ធ ក, ឯកសារ E301/2, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ ("សេចក្តីសន្និដ្ឋានរបស់ ក.ស.ព ទាក់ទិននឹងវិសាលភាព"); សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២, ឯកសារ E301/5/1, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤; សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីអំពីវិសាលភាពនៃសំណុំរឿង ០០២/០២, ឯកសារ E301/5/3, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ ("សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី"); ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឱ្យដាក់សារណា ទាក់ទិននឹងវិសាលភាពសំណុំរឿង ០០២/០២, ឯកសារ E301/5/4, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ ("ចម្លើយតបរបស់ នួន ជា"); *សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២*, ឯកសារ E301/5/2, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ ("សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន")។

[2] សវនាការស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់មុនពេលចាប់ផ្តើមដំណើរការសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ (ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤) (អ.ជ.ស.ដ), ឯកសារ E301/9, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤។

(ដោយហេតុថា អង្គហេតុទាំងនេះពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)[3]។

៣. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ការិយាល័យសហព្រះរាជអាជ្ញា ("សហព្រះរាជអាជ្ញា") បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ចូលទីតាំងឧក្រិដ្ឋកម្មនានាបន្ថែមទៅក្នុងសំណុំរឿង ០០២/០១ [4]។ នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពង្រីកវិសាលនៃការជំនុំជម្រះដើម្បីបញ្ចូលការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ តែមិនបានបញ្ចូលការសម្លាប់ប្រជាជនដែលត្រូវគេជម្លៀសទៅទីតាំងនានាក្នុងស្រុកកំពង់ត្រឡាចលើ ឬ មន្ទីរសន្តិសុខ ស-២១ និង ទីតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅជើងឯកទេ[5]។ នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានស្នើសុំឱ្យធ្វើការ

---

[3] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនទេីរ* នៃវិធានផ្ទៃក្នុង, ឯកសារ E124, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ៥; ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១, ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធិ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163), ឯកសារ E124/7.3, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២។ *សូមមើលផងដែរ* បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២, ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធិ ក្នុងការចូលរួមសវនាការ (E138), ឯកសារ E124/7.2, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[4] សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១, ឯកសារ E163, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២។ នៅថ្ងៃទី ០៣ និងទី១៣ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្តី អៀង សារី និង ក្រុមមេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា (ឯកសារ E163/1 និង ឯកសារ 163/4)។ នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតក្នុងការឆ្លើយតបទៅ អៀង សារី វិញ។ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្តី អៀង សារី បានដាក់សំណើមួយបដិសេធការស្នើសុំការអនុញ្ញាតរបស់សហព្រះរាជអាជ្ញា ក្នុងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមក្នុងវិសាលភាពនៃសវនាការក្នុងសំណុំរឿង ០០២/០១។ វិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានយកមកពិភាក្សាម្តងទៀតក្នុងកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើឡើងនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២។

[5] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន (អ.ជ.ស.ង), ឯកសារ E163/5, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២, កថាខណ្ឌ ១ ដល់ ៣។

កែប្រែឡើងវិញ ដើម្បីបញ្ចូលក្នុងសំណុំរឿង ០០២/០១ នូវអង្គហេតុដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះនាពេលមុន[6]។ នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសមោឃភាពលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងទាំងស្រុង ដោយបានសន្និដ្ឋានថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការនៃសំណុំរឿង០០២ នៅខែ កញ្ញា ឆ្នាំ ២០១១ និង ដីកាសម្រេចនានាបន្តបន្ទាប់ទៀតដែលពាក់ព័ន្ធពុំមានភាពច្បាស់លាស់ និង ពុំមានសំអាងហេតុគ្រប់គ្រាន់។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការសំណុំរឿង ០០២ និង បានកំណត់វិសាលភាពនៃសំណុំរឿង ០០២/០១ ដោយពុំបានផ្តល់ឱកាសពេញលេញដល់ភាគីក្នុងការផ្តល់មតិយោបល់។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យអង្គជំនុំ-ជម្រះសាលាដំបូងពិចារណាជាថ្មីទៅលើបញ្ហានេះ បន្ទាប់ពីបានពិចារណាទៅលើសារណានានារបស់ភាគីរួចមក[7]។

៤. អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់លើកទីពីរនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ដោយមានផ្តល់សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣[8]។ បន្ទាប់ពីស្តាប់មតិយោបល់របស់ភាគីនានាលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីគឺដើម្បីជាប្រយោជន៍យុត្តិធម៌ និងបានកំណត់វិសាលភាពនៃសវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ត្រឹមការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី១ និងទី២ និងការសម្លាប់មនុស្សដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ចំណុចនៃអង្គហេតុដែលត្រូវបានចោទប្រកាន់នេះបង្កើតឱ្យមានតុល្យភាពរវាងកត្តាពាក់ព័ន្ធនានាដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលដើម្បីធានានូវលទ្ធភាពក្នុងការសម្រេចឱ្យបាននូវសាលក្រមមួយក្នុងសំណុំរឿង០០២ ទៅតាមពេលវេលា

---

[6] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ ០០២/០១ មានឧបសម្ព័ន្ធ (I) និង ឧបសម្ព័ន្ធសម្ងាត់ (II), ឯកសារ E163/5/1/1, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២, កថាខណ្ឌ ៣។

[7] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (អ.ជ.ត.ក), ឯកសារ E163/5/1/13, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, កថាខណ្ឌ ៤៨ ដល់ ៥០ ("សេចក្តីសម្រេចលើការបំបែកសំណុំរឿងរបស់ អ.ជ.ត.ក")។

[8] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E284, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

00981705



កំណត់។ អង្គជំនុំជម្រះបានពិចារណាបន្ថែមទៀតថា ការបន្ថែមអង្គហេតុពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ពុំបានបង្កើនជាសត្យានុម័តនូវភាពជាតំណាងសមស្របនៃអង្គហេតុនៅក្នុងសវនាការជំណាក់កាលដំបូងនេះទេ ហើយថា ការពង្រីកវិសាលភាពបន្ថែមទៀតនៃសំណុំរឿង ០០២/០១ នឹងប៉ះពាល់ដល់លទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការចេញសាលក្រមសម្រេចសេចក្តីមួយតាមពេលវេលាកំណត់[9]។

៥. នៅថ្ងៃទី ១០ និង ទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញា និង នួន ជា បានប្តឹងសាទុក្ខជំទាស់នឹងដីកាសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីសវនាការលើកទីពីរ។សហព្រះរាជអាជ្ញាបានស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីបញ្ចូលមន្ទីរសន្តិសុខ ស-២១ ចំណែក នួន ជា បានស្នើសុំឱ្យប្រកាសមោឃភាពលើដីកាសម្រេចនេះទាំងស្រុង ឬ ជាជម្រើសម្យ៉ាងទៀតស្នើសុំឱ្យពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីបញ្ចូលបទល្មើសប្រល័យពូជសាសន៍ និង បទឧក្រិដ្ឋនានាដែលបានចោទប្រកាន់ថាបានកើតឡើងនៅតាមសហករណ៍ និង ការដ្ឋានការងារ[10]។ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា អង្គជំនុំជម្រះនឹងមិនពន្យារពេលក្នុងការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ដែលកំពុងរង់ចាំការសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចបំបែកកិច្ច ដំណើរការនីតិវិធីសវនាការលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងទេ លុះត្រាតែអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីបង្គាប់ឱ្យធ្វើបែបនេះ[11]។ នៅថ្ងៃទី ២៣ ខែ តុលា

---

9 សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E284, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣, កថាខណ្ឌ ១២២, ១៤១, ១៤៧។

10 បណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ទំនាស់នឹងសេចក្តីសម្រេចលើកទីពីរ លើការបំបែកកិច្ចដំណើរការនីតិវិធី, ឯកសារ E284/2/1, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣; បណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី, ឯកសារ E284/4/1, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣។

11 ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ (អ.ជ.ស.ដ), ឯកសារ E288, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣, កថាខណ្ឌ ១០។

ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចសង្ខេបមួយលើបណ្តឹងសាទុក្ខដែលជំទាស់នឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការលើកទីពីរនេះ។ ទោះបីអង្គជំនុំ-ជម្រះតុលាការកំពូលបានបដិសេធបណ្តឹងសាទុក្ខទាំងនោះលើអង្គសេចក្តីក៏ដោយ តែអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សវនាការដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ គួរចាប់ផ្តើមធ្វើឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ រួច និងថា សំណុំ-រឿង ០០២/០២ គួរបញ្ចូលជាអប្បបរមានូវការចោទប្រកាន់នានាដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ ការដ្ឋានការងារ សហករណ៍ និង បទល្មើសប្រល័យពូជសាសន៍[12]។ សំអាងហេតុពេញលេញរបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះសេចក្តីសម្រេចនេះត្រូវបានចេញនៅថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣[13] ក្រោយពេលអង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែនៅមុនពេលមានកិច្ចប្រជុំរៀបចំសវនាការដើម្បីពិចារណាលើបញ្ហានានាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ដែលបានចាប់ផ្តើមនៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣[14]។

៦. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយដែលបង្ហាញពីផែនការការងារសម្រាប់សំណុំរឿង ០០២/០២ និងបានអញ្ជើញភាគីឱ្យដាក់សារណាជាលាយ-លក្ខណ៍អក្សរ ស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២[15]។

## ៣. សារណា

[12] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២៖ សេចក្តីសង្ខេបនៃសំអាងហេតុ (អ.ជ.ត.ក), ឯកសារ E284/4/7, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣, កថាខណ្ឌ ១១ ដល់ ១៣។

[13] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ("សេចក្តីសម្រេចលើការបំបែកសំណុំរឿងលើកទីពីររបស់ អ.ជ.ត.ក"), ឯកសារ E284/4/8, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣, កថាខណ្ឌ ២៨ ដល់ ៧៦។

[14] ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ (អ.ជ.ស.ដ), ឯកសារ E301, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣; ការកំណត់កាលបរិច្ឆេទ និង របៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២ (ពីថ្ងៃទី ១១ ដល់ទី១៣ ខែ ធ្នូ ឆ្នាំ ២០១៣) (អ.ជ.ស.ដ), ឯកសារ E301/3, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣។

[15] ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ (អ.ជ.ស.ដ), ឯកសារ E301/5 ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣, កថាខណ្ឌ ៥; សំណុំរឿង ០០២/០២ - ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង (ពិស្តារ), ឯកសារ E301/5.1, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣។

៧. សហព្រះរាជអាជ្ញាបានលើកឡើងថា បើតាមទិដ្ឋភាពនៃសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីសវនាការលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ជាពិសេសចំពោះលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងសមស្រប និង បទចោទអប្បបរមា និងទីតាំងឧក្រិដ្ឋកម្មនានាដែលបានរៀបរាប់នោះ[16] សំណុំរឿង ០០២/០២ គួរយ៉ាងហោចណាស់គឺបញ្ចូល៖ មន្ទីរសន្តិសុខ ស-២១ (រួមទាំង ជើងឯក)[17] បទល្មើសប្រល័យពូជសាសន៍លើជនជាតិវៀតណាម បទប្រល័យពូជសាសន៍លើជនជាតិចាម (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាដែលពាក់ព័ន្ធ និងការចោទប្រកាន់នានាដែលពាក់ព័ន្ធនឹងការ "បំបែក" ជនជាតិចាមនៅចុងឆ្នាំ ១៩៧៥) ការដ្ឋានទំនប់ ១-មករា (រួមទាំង ការរៀបការដោយបង្ខំ) និង សហករណ៍ត្រាំកក់ (រួមទាំង មន្ទីរសន្តិសុខក្រាំងតាចាន់ និង បទឧក្រិដ្ឋនានាដែលពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើពុទ្ធសាសនិក និងការរៀបការដោយបង្ខំ) ("សំណើសុំរបស់ ក.ស.ព")[18]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងទៀតថា សវនាការគួរតែធ្វើឱ្យមានភាពជាតំណាងកាន់តែច្រើន ដោយរួមបញ្ចូលទាំងទីតាំងឧក្រិដ្ឋកម្មបីបន្ថែមទៀតគឺ៖ ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ អូរកន្សែង និង មន្ទីរសន្តិសុខ ភ្នំក្រោល ("សំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីកបន្ថែម")[19]។

៨. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យរំលេចឱ្យបានសមស្របនូវផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និង បទពិសោធន៍របស់ពួកគេដែលជាជនរងគ្រោះនៅក្នុងការចោទប្រកាន់អង្គហេតុនានា និង នៅក្នុងបទចោទទាំងឡាយណា ដែលត្រូវយកមកជំនុំជម្រះក្នុង

[16] សេចក្តីសន្និដ្ឋានរបស់ ក.ស.ព ទាក់ទិននឹងវិសាលភាព, កថាខណ្ឌ ៩ ដោយដកស្រង់ចេញពី សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីរបស់ អ.ជ.ត.ក, កថាខណ្ឌ ៧៦។

[17] អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា សេចក្តីសន្និដ្ឋានរបស់ ក.ស.ព ទាក់ទិននឹងវិសាលភាពបានបញ្ចូលបឹងជើងឯក (កថាខណ្ឌ ១០) និង ដកចេញព្រៃស (កថាខណ្ឌ ២៧)។ បើតាមសំណើរបស់ ក.ស.ព កថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងមន្ទីរ ស-២១ រួមមាន កថាខណ្ឌ ៤១៥ ដល់ ៤៧៥ ដែលមានកថាខណ្ឌនានាដែលទាក់ទងនឹង ជើងឯក។

[18] សេចក្តីសន្និដ្ឋានរបស់ ក.ស.ព ទាក់ទិននឹងវិសាលភាព, កថាខណ្ឌ ១០, ១២ ដល់ ១៤។

[19] សេចក្តីសន្និដ្ឋានរបស់ ក.ស.ព ទាក់ទិននឹងវិសាលភាព, កថាខណ្ឌ ១៦។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន សហព្រះរាជអាជ្ញាបានរៀបរាប់កថាខណ្ឌនៃដីកាដំណោះស្រាយដែលស្របគ្នានឹងបទឧក្រិដ្ឋ និងទីតាំង។ *សូមមើល ឧទាហរណ៍* សេចក្តីសន្និដ្ឋានរបស់ ក.ស.ព ទាក់ទិននឹងវិសាលភាព, កថាខណ្ឌ ១៨; វិសាលភាពដែលបានស្នើនឹងបញ្ចូលកថាខណ្ឌនានានៃដីកាដំណោះស្រាយពីផ្នែកស្តីពីសហឧក្រិដ្ឋកម្មរួម (JCE) និងតួនាទីរបស់ជនជាប់ចោទដែលពាក់ព័ន្ធនឹងសហករណ៍ និងការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ការប្រព្រឹត្តចំពោះជនជាតិចាម វៀតណាម និងពុទ្ធសាសនិកជន ការរៀបការដោយបង្ខំ និង ជម្លោះប្រដាប់អាវុធ។

00981708



សំណុំរឿង ០០២/០២[20]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមានការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការសំណុំរឿង ០០២ មួយបន្ថែមទៀត ដើម្បីកាត់បន្ថយពេលវេលានៃការរង់ចាំសាលក្រមសម្រេចលើបទចោទនានាដែលនៅសេសសល់ (ក្រៅពីបទចោទនានាដែលបានយកមកជំនុំជម្រះរួចហើយក្នុងសំណុំរឿង ០០២/០១) [21]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានយល់ស្របទៅនឹងសំណើសុំរបស់ ក.ស.ព ដែលបានសុំពង្រីកបន្ថែម។ ជាអាទិភាពទីមួយ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្វែងរកការពង្រីកការចោទប្រកាន់បន្ថែមទៀតពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ(រួមទាំងការរំលោភសេពសន្ថ-វ:) ឱ្យបានវិសាលភាពទូទាំងប្រទេស [22]។ ចំណែកអាទិភាពទីពីរ សហមេធាវីនាំមុខតំណាងដើម-បណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យបន្ថែមអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខ ភូមិភាគឧត្តរ មន្ទីរសន្តិសុខ កោះខ្សង និងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីបី (រួមទាំងការបោសសម្អាតនៅភូមិភាគបូព៌ា) និងសុំឱ្យពង្រីកការចោទប្រកាន់នានាដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិកឱ្យមានទំហំទូទាំងប្រទេសផងដែរ[23]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សំណើនេះឆ្លុះបញ្ចាំងពីលក្ខណៈ ទំហំ និង វិសាលភាពភូមិសាស្ត្រ និងរយៈពេលនៃឧក្រិដ្ឋកម្ម ទីតាំងដែលបានចោទប្រកាន់ទាំងនោះ ហើយថា បទឧក្រិដ្ឋ ឬទីតាំងដែលបានស្នើឡើង មានទំនាក់ទំនងជិតស្និទ្ធទៅនឹងខ្លឹមសារជាសារវន្តនៃសំណុំរឿងទាំងមូល[24]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ការសម្រេចបំបែកកិច្ចដំណើរ-ការនីតិវិធីសវនាការនឹងក្លាយជាវិធីសាស្ត្រដ៏ល្អបំផុតក្នុងការរក្សាតុល្យភាពនៃផលប្រយោជន៍តាមផ្លូវច្បាប់ក្នុងការស្វែងរកការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះវិសាលភាពដ៏ទូលំទូលាយមួយនៃបទឧក្រិដ្ឋ និងការទទួលស្គាល់នូវព្យសនកម្មដែលបានទទួលរង តាមរយៈការចេញសាលក្រមសម្រេចសេចក្តីលើកទីពីរបានឆាប់រហ័ស ដោយគិតទៅដល់អាយុ និងវ័យចំណាស់របស់ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនផងដែរនោះ[25]។

---

[20] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ២។

[21] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៦១ (ភាសាអង់គ្លេស)។

[22] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១០ ដល់ ១៤។

[23] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១, ១៥ ដល់ ៣២។

[24] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ២, ១១ ដល់ ១២, ១៦, ១៨ ដល់ ១៩, ២១ ដល់ ២៣, ២៥ ដល់ ២៧, ២៩ ដល់ ៣១។

[25] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៦០ ដល់ ៦២ (ភាសាអង់គ្លេស)។

៩. មេធាវីការពារក្តី នួន ជា បានលើកឡើងថា ផលប្រយោជន៍ចម្បងរបស់ជនជាប់ចោទជុំវិញការសម្រេចពីវិសាលភាពនៃសំណុំរឿង ០០២/០២ គឺធ្វើយ៉ាងណាឱ្យជនជាប់ចោទមានលទ្ធភាពអាចបន្ថែមភស្តុតាងដោះបន្ទុក ដើម្បីគាំទ្រដល់ការការពារក្តីរបស់ខ្លួន[26]។ មេធាវីការពារក្តីពុំបានបង្ហាញជំហរច្បាស់លាស់លើការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឬ វិសាលភាពសមស្របនៃសំណុំរឿង ០០២/០២ ទេ[27]។ ផ្ទុយទៅវិញ មេធាវីការពារក្តីបានលើកឡើងថា ភស្តុតាងដែលពាក់ព័ន្ធមិនត្រូវដកចេញដោយសារវាមិនមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងទីតាំងឧក្រិដ្ឋកម្មមួយនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីទេ។ មេធាវីការពារក្តីបានលើកឡើងបន្ថែមទៀតថា ភស្តុតាងស្តីពីកម្មវត្ថុនៃរឿងក្តីដែលនៅខាងក្រៅដីកាដំណោះស្រាយ ឧទាហរណ៍ ដែលពាក់ព័ន្ធនឹងចំនួនសរុបនៃអ្នកដែលបានស្លាប់នៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ និងជម្លោះនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាគួរតែត្រូវបានយកចិត្តទុកដាក់ឱ្យបានប្រសើរជាងក្នុងសវនាការលើសំណុំរឿង ០០២/០១[28]។

១០. ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចកំហិតអំពីការបញ្ចូលភស្តុតាងនានាពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនានាដែលបានលើកឡើងនោះ មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះបញ្ចូលទីតាំងឧក្រិដ្ឋកម្មនានាខាងក្រោមទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែរ មានដូចជា៖ ការដ្ឋានទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខ វត្តគិរីរម្យ ឬ វត្តធ្លក គោលនយោបាយនៃការបោសសម្អាតផ្ទៃក្នុង និង ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីបី[29]។ មេធាវីការពារក្តីអះអាងថា អង្គហេតុទាំងនេះមានភាពចាំបាច់សម្រាប់ឱ្យជនជាប់ចោទត្រូវដាក់ដើម្បីការពារក្តី[30]។ មេធាវីការពារក្តី នួន ជា មិនបានជំទាស់នឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំបញ្ចូលការចោទប្រកាន់នានាពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិក និង ការរៀបការដោយបង្ខំក្នុងក្របខណ្ឌទូទាំងប្រទេសឡើយ[31]។ ទោះជាយ៉ាងណាក្តី មេធាវីការពារក្តីជំទាស់នឹងការបញ្ចូលមន្ទីរសន្តិសុខ ស-២១ ដោយសារមន្ទីរនេះមិនមែនតំណាង

---

[26] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ៣។

[27] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៤១ (ភាសាអង់គ្លេស)។

[28] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ៥។

[29] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ៦ ដល់ ៧; ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៤៣ ដល់ ៤៤ (ភាសាអង់គ្លេស)។

[30] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ៧។

[31] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៤៤ (ភាសាអង់គ្លេស)។

ដីកាដំណោះស្រាយ ទាំងមូលនោះទេ "ទោះក្នុងទិដ្ឋភាពណាក៏ដោយ"[32]។ ប្រសិនបើអង្គជំនុំជម្រះសម្រេចបញ្ចូលមន្ទីរ ស-២១ មេធាវីការពារក្តី នួន ជា អាចស្នើសុំប្តឹងជំទាស់ចៅក្រមដែលបានជំនុំជម្រះសំណុំរឿង ០០១ និង សំណុំរឿង ០០២/០១ ដោយសារមេធាវីការពារក្តីលើកឡើងថា ចៅក្រមទាំងនោះនឹងមិនអាចវិនិច្ឆ័យសំណុំរឿង ០០២/០២ ដោយមិនលម្អៀងបានទេ[33]។

១១. មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការចំពោះបទចោទនានាដែលនៅសេសសល់ ដោយបានលើកឡើងថា ការសម្រេចបំបែកកិច្ចដំណើរ-ការនីតិវិធីសវនាការណាមួយនឹងប្រឆាំងនឹងសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលឥតប្រយោជន៍ ដោយសារការជំនុំជម្រះក្តីដែលត្រូវបានសម្រេចបំបែករួចហើយត្រូវចំណាយពេលច្រើនជាងការជំនុំជម្រះនៅក្នុងសវនាការតែមួយ[34]។ មេធាវីការពារក្តីបានលើកឡើងថា ការជំនុំជម្រះមិនត្រូវបំបែកទេ តែគួរតែផ្តោះបញ្ចាំងពីព្រឹត្តិការណ៍ទាំងមូល ដោយហេតុថា សហព្រះរាជអាជ្ញាបានចោទប្រកាន់ ខៀវ សំផន ពីសហឧក្រិដ្ឋកម្មរួមជាប្រព័ន្ធ និង ទៅលើព្រឹត្តិការណ៍ទាំងមូលដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[35]។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការណាមួយទៀត និង លទ្ធភាពដែលអាចនឹងទម្លាក់ចោលបទចោទនានាដែលនៅសេសសល់ ឬ ការបើកសវនាការដំណាក់កាលទីបីនោះ មានន័យថា ជនជាប់ចោទនឹងនៅតែមិនដឹងពីអង្គហេតុជាក់លាក់ដែលជនជាប់ចោទត្រូវប្រឈមជាមួយអស់រយៈពេលជាច្រើនឆ្នាំទៅមុខទៀត [36]។ មេធាវីការពារក្តីបានកត់សម្គាល់ថា លក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងអាចនឹងយកមកប្រើប្រាស់ ប្រសិនបើជនជាប់ចោទមានវ័យចំណាស់ពេក ឬធ្លាក់ខ្លួនឈឺ

---

[32] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៥០ (ភាសាអង់គ្លេស); ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ៨។

[33] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៤៤ ដល់ ៥០ (ភាសាអង់គ្លេស)។ ដោយសារអង្គជំនុំជម្រះតុលាការកំពូលបានបញ្ចូលមន្ទីរ ស-២១ ដោយមិនបានវាយតម្លៃទៅលើភាពជាតំណាងរបស់វានោះ មេធាវីការពារក្តី នួន ជា ផ្តល់យោបល់ថា អង្គជំនុំជម្រះសាលាដំបូងអាចដក មន្ទីរ ស-២១ បានយ៉ាងសមស្របចេញពីវិសាលភាពនៃសំណុំរឿង ០០២/០២ បាន។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៥០ ដល់ ៥១ (ភាសាអង់គ្លេស)។

[34] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន, កថាខណ្ឌ ៣ ដល់ ៦; ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៥២ (ភាសាអង់គ្លេស)។

[35] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន, កថាខណ្ឌ ១៩ ដល់ ២០។

[36] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន, កថាខណ្ឌ ២៥។

ហៀបនឹងលាចាកលោក ជាដើម[37]។ ចុងក្រោយ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា ការពន្យារពេលដែលអាចនឹងបណ្តាលមកពីការសម្រេចសេចក្តីនានាពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីសវនាការ និងការព្រួយបារម្ភពីហានិភ័យដែលជនជាប់ចោទអាចនឹងស្លាប់មុនពេលចេញសាលក្រមលើអង្គសេចក្តីនោះ បានគាំទ្រដល់សំណើរបស់ខ្លួនឱ្យបើកសវនាការដេញដោលលើបទចោទនានាដែលនៅសេសសល់ក្នុងសវនាការតែមួយ[38]។

១២. ក្នុងការឆ្លើយតបទៅនឹងអំណះអំណាងរបស់មេធាវីការពារក្តី នួន ជា ស្តីពីភាពលម្អៀងដែលអាចកើតមាននោះ សហព្រះរាជអាជ្ញាបានលើកឡើងថា ត្រឹមតែការណ៍ដែលចៅក្រមបានស្តាប់សក្ខីកម្មលើអង្គហេតុនានាដែលពាក់ព័ន្ធក្នុងសំណុំរឿងតែមួយនោះ ចៅក្រមទាំងនោះមិនអាចត្រូវបានផិតចិត្តមិនឱ្យស្តាប់សក្ខីកម្មក្នុងសវនាការបន្តបន្ទាប់ទៀតដែលពាក់ព័ន្ធនឹងអង្គហេតុដដែលនោះទេ[39]។ ក្នុងការឆ្លើយតបទៅនឹងមេធាវីការពារក្តី នួន ជា ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះមានការបន្ធូរបន្ថយការរិតត្បិតជាងមុនក្នុងការទទួលយកភស្តុតាងដែលនៅក្រៅវិសាលភាពនៃដីកាដំណោះស្រាយនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ចំណុចនេះផ្ទុយនឹងវិធាន ៨៧ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ហើយ[40]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងដែរថា មន្ទីរ ស-២១ ត្រូវតែបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដោយអនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣[41]។

## ៤. ច្បាប់ជាធរមាន

១៣. នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះអាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងផ្នែកនៃបទចោទនានា ដែលមាននៅក្នុងដីកាដំណោះស្រាយ[42]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា មុនពេលចេញសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ភាគីត្រូវតែទទួលការអញ្ជើញឱ្យផ្តល់អំណះអំណាង ហើយផល

[37] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៥៧ (ភាសាអង់គ្លេស)។

[38] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន, កថាខណ្ឌ ២៩។

[39] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៦៧ ដល់ ៦៨ (ភាសាអង់គ្លេស)។

[40] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៦២ ដល់ ៦៣ (ភាសាអង់គ្លេស)។

[41] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៦៣ (ភាសាអង់គ្លេស)។

[42] វិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង។

ប្រយោជន៍របស់ភាគីត្រូវតែថ្លឹងថ្លែងដោយផ្អែកលើកត្តាពាក់ព័ន្ធទាំងអស់[43]។ ក្នុងការសម្រេចថា តើគួរបំបែកសវនាការ ឬយ៉ាងណានោះ អង្គជំនុំជម្រះត្រូវវាយតម្លៃពីផលប្រយោជន៍ផ្លូវច្បាប់នានាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងគោលការណ៍ដែលប្រកបដោយប្រសិទ្ធភាព[44]។ កត្តាសំខាន់ៗនៅក្នុងការវិភាគនេះរួមមាន ការរំលោភដល់សិទ្ធិរបស់ជនជាប់ចោទដែលអាចនឹងកើតមាន ការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីសវនាការប្រកបដោយប្រសិទ្ធភាព គោលបំណងដែលអាចបញ្ចៀសបាននូវភាពមិនស៊ីសង្វាក់គ្នារវាងសវនាការដាច់ពីគ្នា និងបន្ទុកលើសាក្សីដែលអាចកើតមាន[45]។ កត្តាមួយទៀតដែលអាចគួរពិចារណាផងដែរនោះ គឺថាតើការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីមានភាពចាំបាច់ដែរ ឬទេ ដើម្បីធានាយ៉ាងហោចណាស់ឲ្យមានការជំនុំជម្រះផ្អែកមួយ ចំនួននៃការចោទប្រកាន់ ក្នុងអំឡុងពេលដែលជនជាប់ចោទដែលមានសុខភាពទ្រុឌទ្រោម នៅមានជីវិតនៅឡើយ[46]។

១៤. នៅពេលអង្គជំនុំជម្រះ សម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការមួយទៅជាសវនាការពីរ ឬច្រើនដែលអាចគ្រប់គ្រងបាន បន្ទាប់ពីបានពិចារណារាល់ផលប្រយោជន៍ដែលពាក់ព័ន្ធទាំងអស់ហើយនោះ អង្គជំនុំជម្រះត្រូវតែកំណត់ពីវិសាលភាពនៃសំណុំរឿង ដោយថ្លឹងថ្លែងអំពីលក្ខខណ្ឌតម្រូវនានាដែលថា សវនាការត្រូវតែប្រកបទៅដោយភាពយុត្តិធម៌ និង ឆាប់រហ័ស រួមទាំង “ភាពជាតំណាងសមស្របនៃបទចោទ” នៅក្នុងដីកាដំណោះស្រាយទាំងមូល[47]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់យោបល់ថា កត្តានានាខាងក្រោមអាចធានាដល់ការពិចារណា នៅពេលកំណត់ពីវិសាលភាពនៃសវនាការ៖ (១) បទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ (២) ការចាត់ថ្នាក់ និង លក្ខណៈនៃបទឧក្រិដ្ឋ (៣) ទីកន្លែងដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត (៤) ទំហំនៃបទឧក្រិដ្ឋ (៥) ជនរងគ្រោះនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ (៦) រយៈពេលនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ត្រូវបានប្រព្រឹត្ត និង (៧) លក្ខណៈជាសារវ័ន្តនៃសំណុំរឿង[48]។

## ៥. **សំអាងហេតុ**

---

[43] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីរបស់ អ.ជ.ត.ក, កថាខណ្ឌ ៥០។

[44] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៧, ៤៣។

[45] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៨។

[46] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៥១។

[47] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៦៤។

[48] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៦៤។

១៥. ជាបឋម អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ពីសារណារបស់មេធាវីការពារក្តី នួន ជា ដែលបានលើកឡើងខាងលើពាក់ព័ន្ធនឹងលទ្ធភាពដែលថា មេធាវីការពារក្តីអាចនឹងស្នើសុំជិតចិត្តចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងក្នុងកាលៈទេសៈជាក់លាក់មួយចំនួន។ បញ្ហានេះនៅត្រឹមតែជាទ្រឹស្តីនៅឡើយ ហើយអង្គជំនុំជម្រះនឹងលើកយកមកដោះស្រាយនៅពេលបានទទួលបណ្តឹងជិតចិត្តពិតប្រាកដ[49]។

## ៥.១ សេចក្តីសម្រេចលើការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី

១៦. ពាក់ព័ន្ធនឹងបញ្ហាខាងលើ ជាដំបូងអង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថាតើគួរបំបែកផ្នែកនៃការចោទប្រកាន់នានាដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ឬយ៉ាងណា ដោយផ្អែកលើកត្តាទាំងអស់ដែលពាក់ព័ន្ធ។ ភាគីមានទស្សនៈផ្សេងៗគ្នាលើការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀតក្នុងសំណុំរឿង ០០២។ ទោះបីសហព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀតក៏ដោយ ក៏មេធាវីការពារក្តី ខៀវ សំផន បានជំទាស់មិនឱ្យមានការបំបែកកិច្ចដំណើរការនីតិវិធីណាមួយបន្ថែមទៀតទេ។ មេធាវីការពារក្តី នួន ជា ពុំបានបង្ហាញជំហរគាំទ្រ ឬជំទាស់ទេ តែបានស្នើសុំឱ្យបញ្ចូលទីតាំងឧក្រិដ្ឋកម្មជាក់លាក់បន្ថែមក្នុងករណីមានការបំបែកកិច្ចដំណើរការនីតិវិធី។

១៧. អង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញថា បទចោទ និងទីតាំងឧក្រិដ្ឋកម្ម*អប្បបរមា* ដែលត្រូវបញ្ចូលក្នុងសំណុំរឿង ០០២/០២ រួមមានមន្ទីរ ស-២១ ការដ្ឋានការងារ សហករណ៍ និង បទល្មើសប្រល័យពូជសាសន៍[50]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះមិនបានសម្រេចជាមុនថាតើ ការបំបែកកិច្ចដំណើរការនីតិវិធីចំពោះការចោទប្រកាន់ដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ជាការចាំបាច់ ឬយ៉ាងណាទេ បន្ទាប់ពីសំណុំរឿង ០០២/០១ បានបញ្ចប់។ ហេតុនេះ អង្គជំនុំជម្រះត្រូវពិនិត្យនូវកត្តាទាំងអស់ដែលពាក់ព័ន្ធ ដើម្បីសម្រេចថាតើ មានកាលៈទេសៈចាំបាច់ដែរ ឬទេក្នុងការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀត។

---

[49] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៤៤ ដល់ ៥០ (ភាសាអង់គ្លេស) (មេធាវីការពារក្តី នួន ជា កត់សម្គាល់ថាវាប្រហែលជាការឆាប់រហ័សពេក តែថ្មីឡើតតែយ៉ាងនេះក្តី ដោយបានដកស្រង់នូវការចង្អុលបង្ហាញថា សាលក្រមនៃសំណុំរឿង ០០១ និងសេចក្តីសន្និដ្ឋានដែលអាចមានក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ នឹងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងមិនមានភាពអនាគតិ និងមានភាពលម្អៀង ពាក់ព័ន្ធនឹងបទចោទទាក់ទងនឹងមន្ទីរ ស-២១ ក្នុងសំណុំរឿង ០០២/០២)។

[50] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៧០។

### *៥.១.១ សិទ្ធិរបស់ជនជាប់ចោទ*

១៨. ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងការចោទប្រកាន់នានាដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ត្រូវតែពិនិត្យ *ក្នុងចំណោមនោះ* ពាក់ព័ន្ធនឹងផលប៉ះពាល់ដែលកើតមានដល់សិទ្ធិរបស់ជនជាប់ចោទ រួមមានសិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យារពេលឥតប្រយោជន៍ និងលទ្ធភាពរបស់ពួកគេក្នុងការចូលរួមការរៀបចំការការពារខ្លួនក្នុងសវនាការបន្តបន្ទាប់[51]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មេធាវីការពារក្តី ខៀវ សំផន បានយល់ខុសដែលលើកឡើងថាការបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងការចោទប្រកាន់ដែលនៅសេសសល់នឹងបណ្តាលឱ្យមានការពន្យារពេលឥតប្រយោជន៍ ជាងការបន្តការងារជាមួយនឹងសវនាការតែមួយដែលគ្មានការបំបែក។ ការជំនុំជម្រះលើសំណុំរឿង ០០២ គឺត្រូវការពេលវេលាយូរដែលមិនអាចចៀសរួច ដោយពិចារណាទៅដល់អង្គហេតុនានាដែលបានរៀបរាប់ក្នុងដីកាដំណោះស្រាយដែលមានកម្រាស់រហូតដល់ ៧៧២ ទំព័រ (ភាសាអង់គ្លេស)។ ទោះជាយ៉ាងណាក្តី មេធាវីការពារក្តី ខៀវ សំផន ពុំបានផ្តល់នូវសំអាងហេតុនានាដែលគួរឱ្យជឿជាក់បានដែលបង្ហាញថា ការបំបែកកិច្ចដំណើរការនីតិវិធីសវនាការដែលនៅសេសសល់នាពេលនេះនឹងនាំឱ្យមានដំណើរការវែងឆ្ងាយជាងការបន្តការងារ ជាមួយនឹងសវនាការតែមួយដែលគ្មានការបំបែកនោះឡើយ។

១៩. ជាបឋម មេធាវីការពារក្តី ខៀវ សំផន មិនបានយល់ឱ្យបានត្រឹមត្រូវនូវខ្លឹមសារនៃសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការដែលមេធាវីការពារក្តីលើកទឡ្ហីករណ៍ថា សវនាការដែលបានបំបែកនឹងត្រូវចំណាយពេលច្រើនជាងសវនាការតែមួយចៀសមិនរួចនោះ[52]។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះតុលាការកំពូល

---

[51] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៨, ៤២; អ.ជ.ត.ក ក៏បានកត់សម្គាល់ផងដែរថា "ជាករណីពិសេស សេចក្តីសម្រេចប្រឆាំងនឹងជនជាប់ចោទច្រើននាក់រួមគ្នា" មានភាពស្មុគស្មាញយ៉ាងខ្លាំង មិនមែនដោយសារតែទំនាស់ផលប្រយោជន៍នៃយុទ្ធសាស្ត្រការពារក្តីប៉ុណ្ណោះទេ ប៉ុន្តែ ក៏ដោយសារលទ្ធភាពនៃការចោទប្រកាន់ដាក់គ្នាទៅវិញទៅមករវាងជនជាប់ចោទផងដែរ"។ តែពុំមានមេធាវីការពារក្តីណាមួយក្នុងសំណុំរឿង ០០២ បានលើកឡើងនូវលទ្ធភាពនេះទេ។

[52] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន, កថាខណ្ឌ ៦"*La Cour Suprême a précisé que «les préjudices potentiels aux droits des accusés ont principalement été examinés au regard du droit de ces derniers à être jugé sans délai excessif», les juges considérant notamment que «deux procès successifs […] dureraient inévitablement plus longtemps qu'un procès unique.»*"(គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៥៨ (ភាសាអង់គ្លេស) (ដកស្រង់ចេញពី សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក,

បានពិនិត្យទៅលើយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* ដែលពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធី រួមមាន *រឿងក្តី* *Milošević* និង *រឿងក្តី* *Mladić* ដើម្បីស្វែងរកកត្តានានាដែលគាំទ្រដល់ការពិចារណា ក្នុងការសម្រេចថា តើការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនឹងប៉ះពាល់ដោយមិនត្រឹមត្រូវដល់សិទ្ធិរបស់ជនជាប់ចោទមែន ឬ យ៉ាងណា[53]។ អង្គជំនុំជម្រះតុលាការកំពូលមិនបានលើកឡើងថា ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ នឹងនាំឲ្យមានកិច្ចដំណើរការនីតិវិធីវែងជាងមុនដោយចៀសមិនរួច ឬ មិនបានលើកឡើងថា ប្រការនេះនឹងនាំឲ្យមានការពន្យារពេលឥតប្រយោជន៍នោះទេ។ អង្គជំនុំជម្រះតុលាការកំពូលមិនបានបង្ហាញជំហរថា តើសវនាការពីរដាច់ពីគ្នានឹងត្រូវចំណាយពេលច្រើនជាងសវនាការតែមួយដែលមិនបំបែក ឬ ក្នុងករណីបែបនេះមែន តើកត្តានេះគួរតែត្រូវបានផ្តល់ទម្ងន់ជាងកត្តាផ្សេងៗទៀតដែលពាក់ព័ន្ធ ឬយ៉ាងណានោះទេ[54]។

២០. ជាងនេះទៀត បន្ទាប់ពីបានពិនិត្យទៅលើកាលៈទេសៈនៃអង្គហេតុជាក់លាក់នៅក្នុង *រឿងក្តី* *Milošević* និង *រឿងក្តី* *Mladić* រួចមក មិនមានភាពច្បាស់លាស់ថាតើកង្វល់នានារបស់អង្គជំនុំជម្រះនៃតុលាការ ICTY ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទ អាចយកមកអនុវត្តបានចំពោះការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ដែលអាចមាននោះ ឬយ៉ាងណាទេ។ នៅក្នុង *រឿងក្តី* *Milošević* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានច្រានចោលសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកកិច្ចដំណើរការនីតិវិធីសវនាការ ដោយបានកត់សម្គាល់ជាពិសេសថា កិច្ចដំណើរការនីតិវិធីនឹងត្រូវចំណាយពេលយូរជាងនេះ ប្រសិនបើគេបំបែកសវនាការជាពីរបន្តបន្ទាប់គ្នា[55]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បាន

---

កថាខណ្ឌ ៣៩ សម្រាប់សំណើដែលថា អង្គជំនុំជម្រះត្រូវលើកឡើងក្នុងភស្តុតាងនៃសំណុំរឿង ០០២/០២ ដែលពាក់ព័ន្ធនឹងតួនាទី និងអំណាចរបស់ជនជាប់ចោទ)។ ការពិត អ.ជ.ត.ក បានកត់សម្គាល់ក្នុងកថាខណ្ឌនោះថា "ការបង្ហាញភស្តុតាង អាចបណ្តាលឲ្យមានការត្រួតគ្នា ដោយពិចារណាថា ភស្តុតាងមួយចំនួន ឧទាហរណ៍ពាក់ព័ន្ធនឹងតួនាទី និងអំណាចរបស់ជនជាប់ចោទ ទំនងជាត្រូវមកយកបង្ហាញ និងពិចារណា ក្នុងសវនាការនីមួយៗ") *សូមមើល* សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៩ (គូសបញ្ជាក់បន្ថែម)។

[53] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៧ ដល់ ៤០។

[54] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៨, ៥១, ៥២។

[55] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milošević*, សំណុំរឿងលេខ IT-99-37-AR73, សំអាងហេតុសម្រាប់ការសម្រេចទៅលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំរបស់អយ្យការជំទាស់ទៅនឹងការបដិសេធក្នុងការចេញដីការួម, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២, កថាខណ្ឌ ២៧។

ពិចារណាថា សវនាការពីរបន្តបន្ទាប់គ្នានឹងមានការលំបាកជាពិសេសចំពោះ Milošević ដោយសារគាត់ត្រូវការពារខ្លួនដោយខ្លួនឯង។ សំណុំរឿង ០០២ ខុសគ្នាស្រឡះជាមួយសំណុំរឿងខាងលើ ដោយហេតុថា ជនជាប់ចោទទាំងពីរនាក់ត្រូវបានតំណាងដោយក្រុមមេធាវីការពារក្តីរៀងៗខ្លួន។

២១. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុង *រឿងក្តី Mladić* ក៏បានពិចារណាផងដែរថា ការបំបែកកិច្ចដំណើរការនីតិវិធីសវនាការ និងការជំនុំជម្រះនៅក្នុងសវនាការពីរផ្សេងគ្នាអាចនឹងប៉ះពាល់ដល់ជនជាប់ចោទ ដោយសារវាអាចជាបន្ទុកធ្ងន់ពេកសម្រាប់ជនជាប់ចោទ *Mladić* ក្នុងការចូលរួមនៅក្នុងការរៀបចំសម្រាប់ត្រៀមសវនាការនៅក្នុងរឿងក្តីមួយ ទន្ទឹមនឹងនោះក៏ត្រូវបន្តចូលរួមក្នុងសវនាការលើអង្គសេចក្តី ឬ រៀបចំប្តឹងសាទុក្ខក្នុងរឿងក្តីមួយទៀត[56]។ អង្គជំនុំជម្រះខាងលើបានពិចារណាថា សេចក្តីត្រូវការក្នុងការសម្របសម្រួលការងាររវាងមេធាវីការពារក្តីពីរក្រុមដាច់ដោយឡែកពីគ្នាដែលតំណាងឱ្យជនជាប់ចោទតែមួយក្នុងអំឡុងពេលមានកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធ និងនាំឱ្យមានភាពស្មុគស្មាញដល់លទ្ធភាពរបស់ជនជាប់ចោទក្នុងការចូលរួមក្នុងការរៀបចំការការពារខ្លួនរបស់គាត់[57]។ ពាក់ព័ន្ធនឹងសំណុំរឿង ០០២ វិញ អង្គជំនុំជម្រះកត់សម្គាល់ថា កិច្ចស៊ើបសួរត្រូវបានធ្វើឡើងរួចរាល់ ហើយនីតិវិធីមុនអង្គសេចក្តីជាច្រើនត្រូវបានដោះស្រាយរួចរាល់ហើយដែរ រួមទាំងការសម្រេចលើអញ្ញត្រកម្មជាច្រើន[58] រួមទាំងបញ្ជីឈ្មោះសាក្សី

[56] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mladić,* សំណុំរឿងលេខ IT-09-92-PT, សេចក្តីសម្រេចលើសំណើរួមរបស់អយ្យការដែលសុំបំបែកដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីរៀបចំសវនាការច្រើន និង សុំកែប្រែដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១, កថាខណ្ឌ ៣១។

[57] សេចក្តីសម្រេចលើ *រឿងក្តី Mladić*, កថាខណ្ឌ ៣១។

[58] *សូមមើល ឧទាហរណ៍,* សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ, ឯកសារ E51/14, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១; សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92), ឯកសារ E116, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១; សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, ឯកសារ E100/6, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១; សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ), ឯកសារ E122, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១; សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឯកសារ E95/8, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១; ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់ជនជាប់ចោទ នួន ជា ដែលស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ជាបណ្តោះអាសន្ន (ឯកសារ E131/2), ឯកសារ E131/2/1, ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១; សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងអនុគ្រោះទោស), ឯកសារ E51/15, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១។

បឋមសម្រាប់សំណុំរឿង ០០២ ទាំងមូលផងដែរ[59]។ ជាងនេះទៀត ជនជាប់ចោទក្នុងសំណុំរឿង ០០២ ត្រូវបានតំណាងដោយមេធាវីការពារក្តីតែមួយក្រុមសម្រាប់ជនជាប់ចោទនីមួយៗ ហេតុនេះ ជនជាប់ចោទពុំត្រូវចាំបាច់សម្របសម្រួលរវាងក្រុមមេធាវីពីរក្រុមផ្សេងគ្នានោះទេ។

២២. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការបំបែកកិច្ចដំណើរការនីតិវិធីដែលនៅសេសសល់ នឹងមិននាំឱ្យមានការពន្យារពេលឥតប្រយោជន៍ ដោយការតម្រូវឱ្យមានការផ្អាកសវនាការទីពីរ ដើម្បីទុកពេលវេលាគ្រប់គ្រាន់សម្រាប់ជនជាប់ចោទក្នុងការរៀបចំរឿងក្តីរបស់ខ្លួនទេ[60]។ ខុសពីនៅតុលាការ ICTY នៅ អ.វ.ត.ក ក្រុមមេធាវីការពារក្តីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាំងពីដំណាក់កាលស៊ើបអង្កេតមកម្ល៉េះ។ ខៀវ សំផន និង នួន ជា ទទួលបានជំនួយមេធាវីការពារក្តីពួកគាត់ ដែលតែងតាំងដោយតុលាការតាំងពីចុងឆ្នាំ ២០០៧ មកម្ល៉េះ[61] ហើយក្រុមមេធាវីការពារក្តីនីមួយៗមានពេលវេលា និងធនធានគ្រប់គ្រាន់ដើម្បីរៀបចំរឿងក្តីរបស់ខ្លួនទល់នឹងបទចោទនានាក្នុងដីកាដំណោះស្រាយទាំងមូល[62]។ អង្គជំនុំជម្រះរំពឹងថា នឹងពុំមានការពន្យារកិច្ចដំណើរការនីតិវិធី

---

[59] *សូមមើល ឧទាហរណ៍*, បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និង ទី៥, ឯកសារ E9/4, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១; បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់១, ២ក, ២ខ, ៣ក, ៣ខ និង ៤, ឯកសារ E9/4/3, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១; បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើឡើង, ឯកសារ E9/4/4, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១; បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែល ខៀវ សំផន បានស្នើសុំ, ឯកសារ E9/4/6, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។

[60] ប្រៀបធៀប សេចក្តីសម្រេចលើ *រឿងក្តី Mladić*, កថាខណ្ឌ ៣២។

[61] ការតែងតាំងលោក សាយ បូរី និង លោក Jacques Vergès ជាមេធាវីរបស់ ខៀវ សំផន ដោយអង្គភាពគាំពារការពារក្តី (DSS), ឯកសារ A116, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៨ (ដោយជូនដំណឹងស្តីពីការតែងតាំងមេធាវីការពារក្តីបណ្តោះអាសន្ននៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧); ការតែងតាំងលោក សុន អរុណ និង លោក Victor KOPPE ជាមេធាវីរបស់ នួន ជា ដោយ DSS, ឯកសារ A119, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨ (ដោយជូនដំណឹងស្តីពីការតែងតាំងមេធាវី សុន អរុណ ចាប់ពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ និងលោក Michael PESTMAN និងលោក Victor KOPPE ពីថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧); ការតែងតាំងលោក សុន អរុណ និង លោក Michael PESTMAN ជាមេធាវីរបស់ នួន ជា ដោយ DSS, ឯកសារ A143, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨។

[62] *សូមមើល ផងដែរ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើនានាដែលស្នើសុំពន្យារពេលដើម្បីដាក់ការជំទាស់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (ឯកសារ E9/7 និង E9/4/9), ឯកសារ E9/7/1, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១; សេចក្តីសម្រេច លើសំណើនានាដែលស្នើសុំពន្យារពេលដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាង, ឯកសារ E9/16/4, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១។

បន្តបន្ទាប់នោះទេ ដោយពិចារណាពីសេចក្តីត្រូវការចាំបាច់ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីត្រូវបានដំណើរការក្នុងពេលវេលាសមស្រប ដើម្បីធានាពីការសម្រេចស្ពាពរមួយចំពោះការចោទប្រកាន់នានាដែលនៅសេសសល់ និង ដើម្បីចាប់ផ្តើមសំណុំរឿង ០០២/០២ ឲ្យបានកាន់តែឆាប់រហ័សតាមដែលអាចធ្វើទៅបាន[63]។

២៣. ទឡ្ហីករណ៍ដែលថា ការបំបែកកិច្ចដំណើរការនីតិវិធីនឹងបណ្តាលឲ្យមានការពន្យារពេលឥតប្រយោជន៍នោះ ពុំមែនកើតឡើងដោយសារបទពិសោធន៍នៃសំណុំរឿង០០២ ទេ។ ដូចដែលអង្គជំនុំជម្រះធ្លាប់បានកត់សម្គាល់តាំងពីពេលចាប់ផ្តើមសវនាការមកម៉្លេះថា សំណុំរឿង ០០២/០១ នឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការពិនិត្យពិស្តារបន្ថែមទៀតចំពោះការចោទប្រកាន់នានាដែលនៅសេសសល់ និងការចោទប្រកាន់អង្គហេតុប្រឆាំងនឹងជនជាប់ចោទនៅក្នុងសវនាការបន្តបន្ទាប់ទៀត[64]។ ដោយសំអាងលើមូលដ្ឋានគ្រឹះនេះ សំណុំរឿង ០០២/០២ នឹងមានភាពរលូន និងធានាដល់ការបញ្ចប់នូវសំណុំរឿងនេះបានឆាប់រហ័ស។ ឧទាហរណ៍ ការពិចារណាពីភាពទទួលយកបាននៃភស្តុតាងក្នុងសំណុំរឿង ០០២/០១ គឺជាដំណើរការដែលបានចំណាយពេល និងធនធានជាច្រើន[65]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់ថា ភស្តុតាងនានាដែលបានដាក់នៅចំពោះ

---

[63] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៧២; សូមមើល ផងដែរ, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ ខៀវ សំផន សុំពន្យាពេលសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរលើសំណុំរឿង ០០២/០១; ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារ នាពេលខាងមុខ, ឯកសារ E301/5 ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣; សវនាការស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់មុនពេលចាប់ផ្តើមដំណើរការសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ (ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤) (អ.ជ.ស.ង), ឯកសារ E301/9, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤។

[64] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ឯកសារ E124/7, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, កថាខណ្ឌ ១០; សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E284, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣, កថាខណ្ឌ ១៥។

[65] ឧទាហរណ៍នៃសេចក្តីសម្រេចនានាដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហានៃភាពទទួលយកបាននៃភស្តុតាងក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ រួមមាន៖ ការឆ្លើយតបទៅនឹងបញ្ហានានាដែលភាគីបានលើកឡើងមុនពេលសវនាការ និងការកំណត់កាលបរិច្ឆេទនៃការប្រជុំជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ង), ឯកសារ E141, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៥; ការកំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់ស្តីពីឯកសារ (ថ្ងៃទី ១៦ ដល់ ១៩ ខែ មករា ឆ្នាំ ២០១២) (អ.ជ.ស.ង), ឯកសារ E159, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២; ការកំណត់

មុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ រួចហើយនឹងអាចយកមកប្រើប្រាស់សម្រាប់សំណុំរឿង ០០២/០២ ទៀត[66]។ ចំណុចនេះនឹងបង្កើតឱ្យមានប្រសិទ្ធភាពជាក់លាក់ ដោយសារថិរវេលា និង ធនធានរបស់តុលាការចាំបាច់ដើម្បីដំណើរការនីតិវិធីទាំងនេះត្រូវបានកំហិតត្រឹមតែក្នុងដំណាក់-កាលសវនាការបន្តបន្ទាប់ប៉ុណ្ណោះ។ ជាងនេះទៀត សាក្សីមួយចំនួនដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទាំងមូលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ រួចហើយ។ទោះបីអង្គជំនុំជម្រះសាលា-ដំបូងនឹងធ្វើការវាយតម្លៃដោយផ្អែកលើករណីជាក់ស្តែងក៏ដោយ ក៏ចំណុចនេះបានកាត់បន្ថយនូវសេចក្តីត្រូវការចាំបាច់សម្រាប់សាក្សីមួយចំនួនដែលត្រូវកោះហៅសាជាថ្មីក្នុងដំណាក់កាលបន្តបន្ទាប់នៃសំណុំរឿង ០០២។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា មេធាវីការពារក្តី ខៀវ សំផន មិនបានចង្អុលបង្ហាញថា ការបំបែកសវនាការមួយ ឬ ច្រើននឹងនាំឱ្យមានការពន្យារពេលឥតប្រយោជន៍នោះទេ ជាពិសេស នៅពេលពិចារណាពីគុណសម្បត្តិនៃការទទួលបានសាល-ក្រមមួយ ដែលយ៉ាងហោចណាស់ក៏មានបទចោទមួយចំនួនក្នុងដីកាដំណោះស្រាយដែរ ក្នុងពេលដែលជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះនៅរស់រានមានជីវិត[67]។

២៤. ទោះបីមេធាវីការពារក្តី ខៀវ សំផន ពីដំបូងធ្លាប់បានយល់ស្របនឹងការបំបែកកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២ ក៏ដោយ តែពេលនេះមេធាវីការពារក្តីបានអះអាងថា ខៀវ សំផន ត្រូវទទួលរងការប៉ះពាល់ដោយសារកង្វះភាពដែលអាចប្រមើលមើលបានក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងការចោទប្រកាន់នានាដែលកំពុងពិភាក្សា ហើយថា ការប៉ះពាល់នេះនឹងនៅតែមានក្នុងដំណាក់កាលបន្តបន្ទាប់ទៀត ប្រសិនបើការចោទប្រកាន់អង្គហេតុដែលនៅសេសសល់

---

កាលបរិច្ឆេទសវនាការផ្ទាល់មាត់ស្តីពីឯកសារ (ថ្ងៃទី ១៣ ដល់ ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) (អ.ជ.ស.ដ), ឯកសារ E170, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២; បច្ចុប្បន្នភាពនៃអនុស្សរណៈសម្រាប់សវនាការលើឯកសារពេលបន្ទាប់ (ថ្ងៃទី ១២ ដល់ទី ១៩ ខែ មីនា ឆ្នាំ ២០១២) (អ.ជ.ស.ដ), ឯកសារ E172/5, ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២; សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារនានាដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅលើឧបសម្ព័ន្ធ ក១ ដល់ ក៥ របស់សហព្រះរាជអាជ្ញា និង ឯកសារដែលបានឯកសារក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១, ឯកសារ E185, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២; សេចក្តីសម្រេចពាក់ព័ន្ធនឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធផ្សេងៗទៀត, ឯកសារ E190, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២។

[66] ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ (អ.ជ.ស.ដ), ឯកសារ E302/5, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤, កថាខណ្ឌ ៧។

[67] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៥១។

ត្រូវបានបំបែកនោះ[68]។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះកត់សម្គាល់ពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា កង្វល់ពីភាពដែលអាចព្យាករណ៍បាន និងសច្ចភាពរបស់តុលាការពាក់ព័ន្ធនឹងសំណុំរឿង ០០២ ជារួម ពុំមានមូលដ្ឋានទេ ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ បន្ទាប់ពីមានការបញ្ជាក់បំភ្លឺពីអង្គជំនុំជម្រះតុលាការកំពូលរួចហើយ[69]។ អង្គជំនុំជម្រះសាលាដំបូងចាត់ទុកកាលៈទេសៈបច្ចុប្បន្នថាមានលក្ខណៈស្រដៀងគ្នាទៅនឹងការលើកឡើងខាងលើដោយអង្គជំនុំជម្រះតុលាការកំពូល។ប្រសិនបើការបំបែកកិច្ចដំណើរការនីតិវិធីសវនាការត្រូវបានសម្រេចនោះ ដូច្នេះអត្តសញ្ញាណនៃកថាខណ្ឌនានាដែលពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយនឹងផ្តល់ការជូនដំណឹងដល់ជនជាប់ចោទពីវិសាលភាពនៃសវនាការមួយ ឬច្រើនបន្តបន្ទាប់ជាមិនខាន។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា នាពេលនេះ ភាគីមានឱកាសគ្រប់គ្រាន់ក្នុងការពិនិត្យភ័ស្តុតាងក្នុងសំណុំរឿង និងលើកឡើងនូវការជំទាស់អនុលោមតាមវិធានផ្ទៃក្នុង។អង្គជំនុំ-ជម្រះសាលាដំបូងយល់ឃើញថា ការចេញសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីដែលកំណត់ច្បាស់ពីវិសាលភាពនៃដំណាក់កាលបន្ទាប់នៃសវនាការ និងជាការជូនដំណឹងដល់ជន-ជាប់ចោទនូវការចោទប្រកាន់នានាប្រឆាំងនឹងពួកគេនឹងអនុញ្ញាតឱ្យពួកគេបានចូលរួមក្នុងការ រៀបចំការការពារខ្លួនបាន។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា សិទ្ធិរបស់ជនជាប់ចោទមិនត្រូវបានប៉ះពាល់ជាអវិជ្ជមាន ដោយសារកង្វះភាពអាចប្រមើលមើលបាន ឬបញ្ហាកង្វល់ផ្សេងៗទៀត ក្នុងករណីមានការបំបែកកិច្ចដំណើរការនីតិវិធីនោះឡើយ។

២៥. ដោយបានពិចារណាដល់ផលប៉ះពាល់ដែលអាចកើតមានដល់សិទ្ធិរបស់ជនជាប់ចោទនោះ នាពេលនេះ អង្គជំនុំជម្រះពិនិត្យទៅលើកត្តានានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងដំណើរការនីតិវិធីវិញម្តង។

### ៥.១.២ ប្រសិទ្ធភាព និងភាពអាចគ្រប់គ្រងបាននៃកិច្ចដំណើរការនីតិវិធី

២៦. សហព្រះរាជអាជ្ញាបានស្នើសុំឱ្យមានការបំបែកកិច្ចដំណើរការនីតិវិធីសវនាការមួយបន្ថែមទៀតដែលវិសាលភាពនៃសំណុំរឿងដែលត្រូវបានបំបែកនោះនឹងបញ្ចូលសាក្សី អ្នកជំនាញ និង ដើម-បណ្តឹងរដ្ឋប្បវេណីចំនួន៩៦រូប ដែលស្នើឡើងដោយ ក.ស.ព។ បើតាមការប៉ាន់ស្មាន សហព្រះរាជ-

[68] សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម, ឯកសារ E275/2/1/1, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣, កថាខណ្ឌ ៤២, ៥២; ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៣៣ (ភាសាអង់គ្លេស)។

[69] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើសុំដោះលែង ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់, ឯកសារ E275/2/3, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣, កថាខណ្ឌ ៥២។

អាជ្ញាត្រូវការពេលវេលាចំនួនពីរទៅបីឆ្នាំ ដើម្បីអាចបញ្ចប់សវនាការដែលបានបំបែកនេះ (ដែលក្នុងនោះ រយៈពេលមួយឆ្នាំ ទៀងប់ប្រាំបីខែ សម្រាប់សវនាការដេញដោលលើភស្តុតាង) អនុលោមទៅតាមសំណើរបស់ ក.ស.ព ដែលត្រូវបានពង្រីកបន្ថែម[70]។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា ចំណុចនេះនឹងបញ្ចូល*ការចោទប្រកាន់*ទាំងអស់ក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ទោះបីមិនបានគ្រប់*អង្គហេតុ*ទាំងអស់នៅក្នុងដីកាដំណោះស្រាយក៏ដោយ[71]។ ទោះជាយ៉ាងនេះក្តី ការបំបែកកិច្ចដំណើរការនីតិវិធីបែបនេះនឹងនាំឱ្យមានការកាត់បន្ថយយ៉ាងច្រើនចំពោះចំនួនសាក្សីដែលតម្រូវដើម្បីស្តាប់សក្ខីកម្មនៅសវនាការ និងនាំឱ្យមានកិច្ចដំណើរការនីតិវិធីដែលអាចគ្រប់គ្រងបានជាងមុន។ ឧទាហរណ៍ បញ្ជីឈ្មោះសាក្សីពីដើមដំបូងរបស់សហព្រះរាជអាជ្ញាដែលបានដាក់នៅឆ្នាំ ២០១១ សម្រាប់សំណុំរឿង ០០២ ទាំងមូល មានសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញចំនួន ២៩៥ នាក់ ដើម្បីស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២[72]។ ក្នុងចំនួននោះមាន ៥៨នាក់បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១។ ហេតុនេះ យ៉ាងហោចណាស់ក៏នៅមានសាក្សីចំនួន ២៣៧ នាក់ ទៀតពីបញ្ជីឈ្មោះសាក្សីពីដើមដំបូងរបស់សហព្រះរាជអាជ្ញាដែលត្រូវផ្តល់សក្ខីកម្ម។ កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណីរបស់ ក.ស.ព ចំនួន ៩៦ នាក់ច្បាស់ជាអាចគ្រប់គ្រងបានជាងពេលកោះហៅចំនួន ២៣៧ មកផ្តល់សក្ខីកម្ម ជាពិសេសដោយសារថា ភាគីផ្សេងៗទៀតទាំងអស់ក៏នឹងស្នើសុំឱ្យសាក្សីរបស់ខ្លួនមកផ្តល់សក្ខីកម្មដែរ។ នៅឆ្នាំ ២០១១ មេធាវីការពារក្តី នួន ជា បានដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ

[70] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៧៣ (ភាសាអង់គ្លេស); សេចក្តីសន្និដ្ឋានរបស់ ក.ស.ព ស្តីពីវិសាលភាព, កថាខណ្ឌ ២០; ផែនការសវនាការសម្រាប់សំណុំរឿង ០០២/០២ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា (ជាមួយ ឧបសម្ព័ន្ធសម្ងាត់ ក), ឯកសារ E301/2/1, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៣, កថាខណ្ឌ ២; ឧបសម្ព័ន្ធ ក៖ ផែនការសវនាការ និងបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្នរបស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង ០០២/០២, ឯកសារ E301/2/1.1, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៣។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងថា សហព្រះរាជអាជ្ញាធ្លាប់បានអះអាងក្នុងពេលប្រជុំរៀបចំសវនាការថា សវនាការមួយដែលនឹងដំណើរការទៅតាមវិសាលភាពដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា នឹងត្រូវចំណាយពេលពី ១២ ទៅ ១៨ ខែ ទើបចប់សព្វគ្រប់ តែក្រោយមកអះអាងថា រយៈពេល ០២ ទៅ ០៣ ឆ្នាំទើបសុក្រឹតជាង៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣, ទំព័រ ៥៦ ដល់ ៥៨ (ភាសាអង់គ្លេស)។

[71] ផែនការសវនាការសម្រាប់សំណុំរឿង ០០២/០២ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា (ជាមួយ ឧបសម្ព័ន្ធសម្ងាត់ ក), ឯកសារ E301/2/1, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៣; ឧបសម្ព័ន្ធ ក៖ ផែនការសវនាការ និងបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្នរបស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង ០០២/០២, ឯកសារ E301/2/1.1, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៣។

[72] ឧបសម្ព័ន្ធ ១៖ សំណើបង្គាប់ឱ្យសាក្សីចូលបង្ហាញខ្លួនក្នុងសវនាការ៖បញ្ជីឈ្មោះរួមបញ្ចូលគ្នានៃ អ្នកជំនាញ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារ E9/4.1, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។

និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥៤៥ នាក់ដើម្បីមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២[73]។ មេធាវីការពារក្តី ខៀវ សំផន និង ដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនយ៉ាងវែងដែរ[74]។ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក្នុងចំណោមនោះពុំអាចទាក់ទងបាន ឬវត្តមានរបស់ពួកគេនៅពេលសវនាការត្រូវបានចាត់ទុកថាមិនពាក់ព័ន្ធ។ ជាងនេះទៀត ភាគីអាចនឹងជំទាស់នឹងសំណើសុំស្តាប់សក្ខីកម្មបុគ្គលមួយចំនួនដើម្បីសន្សំពេលវេលា និងចៀសវាងភាពច្រំដែលផង។ ថ្វីត្បិតតែយ៉ាងនេះក្តី សវនាការនៃសំណុំរឿង ០០២ នឹងពាក់ព័ន្ធជាមួយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ច្រើនជាងសំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីកទៅទៀត។

២៧. ការប៉ាន់ស្មានមួយទៀតពីទំហំនៃផ្នែកដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយនោះ គឺចំនួនកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយដែលនៅសេសសល់ដែលត្រូវដោះស្រាយ។ ដីកាដំណោះស្រាយនៃសំណុំរឿង ០០២ រួមមានកថាខណ្ឌចំនួន ១៦២៤ ដែល កថាខណ្ឌចំនួន ៤៧៧ ត្រូវបានបញ្ចូលក្នុងសំណុំរឿង ០០២/០១[75]។ បើពុំមានការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀតទេនោះ សំណុំរឿង ០០២/០២ ចាំបាច់ត្រូវដោះស្រាយយ៉ាងហោចណាស់ក៏កថាខណ្ឌចំនួន ១១៤៧ នៃដីកាដំណោះស្រាយថែមទៀតដែរ។ សវនាការដែលពាក់ព័ន្ធនឹងវិសាលភាពធំធេងផ្នែកភូមិសាស្ត្រ និងទីតាំងឧក្រិដ្ឋកម្ម បន្ថែមទៅលើចំនួនសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដ៏ច្រើនលើសលប់នោះ វានឹងនាំឱ្យមានការលំបាកជាខ្លាំងក្នុងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងឆាប់រហ័ស។ បញ្ហាកង្វល់ធំៗពាក់ព័ន្ធនឹងសុខភាពរបស់

---

[73] បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែល នួន ជា បានស្នើឡើង, ឯកសារ E9/4/4, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។

[74] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែល ខៀវ សំផន បានស្នើសុំ, ឯកសារ E9/4/6, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១; បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់១, ២ក, ២ខ, ៣ក, ៣ខ និង ៤, ឯកសារ E9/4/3, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។

[75] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១, ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163), ឯកសារ E124/7.3, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២។

ជនជាប់ចោទ ក៏ជាកត្តាចម្បងមួយដែលអង្គជំនុំជម្រះត្រូវយកមកពិចារណាដែរ មុនពេលសម្រេចដំណើរការសវនាការដែលចំណាយពេលដ៏យូរនេះ[76]។

២៨. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានកត់សម្គាល់ពីកង្វល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលចង់ឲ្យចេញសាលក្រមមួយឲ្យបានកាន់តែឆាប់កាន់តែប្រសើរ ដោយសារដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន ដែលមានវ័យចាស់ និងសុខភាពទ្រុឌទ្រោមផង អាចបានឃើញភាពយុត្តិធម៌ នៅពេលពួកគាត់នៅរស់រានមានជីវិត[77]។ អង្គជំនុំជម្រះសន្និដ្ឋានថា ការបំបែកកិច្ចដំណើរការនីតិវិធីសវនាការនៃសំណុំរឿង ០០២ បន្ថែមទៀត នឹងកាត់បន្ថយពេលវេលានៃការរង់ចាំសាលក្រមលើបទចោទមួយចំនួន ដែលនឹងបំពេញតាមបំណងប្រាថ្នានេះ ដោយរក្សាបាននូវគុណភាពនៃសិទ្ធិរបស់ជនជាប់ចោទផងដែរ។ អង្គជំនុំជម្រះបានពិចារណាទៅលើបន្ទុកធ្ងន់ធ្ងរដែលអាចធ្លាក់លើសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និង អ្នកជំនាញដែលត្រូវកោះហៅមកផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ហើយនឹងត្រូវកោះហៅសាជាថ្មីក្នុងកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់ ក្នុងករណីដែលបទចោទនៅសេសសល់ត្រូវបានបំបែក។ ទោះបីជាវិសាលភាពនៃកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់មិនទាន់បានកំណត់ក៏ដោយ ក៏អង្គជំនុំជម្រះពិចារណាថា បុគ្គលដែលអាចនឹងត្រូវកោះហៅសាជាថ្មីបន្ទាប់ពីបានបង្ហាញខ្លួនក្នុងសំណុំរឿង ០០២/០២ នឹងមានចំនួនតិចតួចប៉ុណ្ណោះ[78]។ ដូចដែលអង្គជំនុំជម្រះបានចង្អុលបង្ហាញនាពេលថ្មីៗនេះថា វិធានផ្ទៃក្នុងបានបង្កើតនូវក្របខណ្ឌគតិយុត្តមួយសម្រាប់ការកោះហៅសាជាថ្មីនូវសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ[79]។ វិធានផ្ទៃក្នុងនឹង

[76] នាពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងកំពុងវាយតម្លៃពីសុខភាពរបស់ជនជាប់ចោទ។ *សូមមើល* សេចក្ដីសម្រេចលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ និងដីកាចាត់តាំងអ្នកជំនាញ, ឯកសារ E301/10, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤។

[77] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៦១ (ភាសាអង់គ្លេស)។

[78] ឧទាហរណ៍ មានតែសាក្សីបីនាក់ប៉ុណ្ណោះ ក្នុងចំណោមសាក្សីចំនួន ៩៦ នាក់ដែលសហព្រះរាជអាជ្ញាបានស្នើសុំសម្រាប់សំណុំរឿង ០០២/០២ ដែលនឹងត្រូវកោះហៅសាជាថ្មីពីសំណុំរឿង ០០២/០១៖ ផែនការសវនាការសម្រាប់សំណុំរឿង ០០២/០២ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា (ជាមួយ ឧបសម្ព័ន្ធសម្ងាត់ ក), ឯកសារ E301/2/1, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៣, ឧបសម្ព័ន្ធ ក៖ ផែនការសវនាការ និងបញ្ជីឈ្មោះសាក្សីបណ្ដោះអាសន្នរបស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង ០០២/០២, ឯកសារ E301/2/1.1, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៣។

[79] ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ (អ.ជ.ស.ដ), ឯកសារ E302/5, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ៨។

ដើរតួនាទីជាអ្នកការពារប្រឆាំងនឹងភ័ស្តុតាងដែលមិនពាក់ព័ន្ធ ឬច្រំដែល ហើយនឹងកំហិតតែទៅលើភ័ស្តុតាងដែលចាំបាច់តែប៉ុណ្ណោះ។ អង្គជំនុំជម្រះសន្និដ្ឋានថា ការកោះហៅសាក្សីសាជាថ្មីដែលបណ្តាលមកពីការបំបែកកិច្ចដំណើរការនីតិវិធីសវនាការបន្ថែមទៀតនឹងត្រូវកំហិត។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនគួរជំទាស់នឹងការបំបែកកិច្ចដំណើរការនីតិវិធីសវនាការនេះទេ។

២៩. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដល់តម្រូវការចាំបាច់ក្នុងការបញ្ចៀសនូវភាពមិនស៊ីសង្វាក់គ្នារវាងសវនាការដាច់ៗពីគ្នា។ ដោយសារអង្គជំនុំជម្រះសាលាដំបូងនឹងអនុវត្តក្របខណ្ឌច្បាប់តែមួយ និង វិធាននៃភ័ស្តុតាងនិងនីតិវិធីតែមួយ ក្នុងដំណាក់កាលនីមួយៗនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ នោះ អង្គជំនុំជម្រះសន្និដ្ឋានថាហានិភ័យណាមួយនៃភាពមិនស៊ីសង្វាក់គ្នារវាងដំណាក់កាលដាច់ៗពីគ្នានឹងមានកំរិតទាប និងមិនក្លាយជាឧបសគ្គចំពោះការបំបែកកិច្ចដំណើរការនីតិវិធីសវនាការនេះទេ។

៣០. តាមសំអាងហេតុនានាដូចដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះយល់ឃើញថា ការបំបែកកិច្ច-ដំណើរការនីតិវិធីសវនាការនៃសំណុំរឿង ០០២ បន្ថែមទៀត គឺជាប្រយោជន៍នៃយុត្តិធម៌ និងមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទឡើយ។

## ៥.២ __សេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង ០០២/០២__

៣១. ពាក់ព័ន្ធនឹងសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា សំណុំរឿង ០០២/០២ “ត្រូវមានយ៉ាងហោចណាស់ ការចោទប្រកាន់អង្គហេតុពាក់ព័ន្ធនឹងមន្ទីរ ស-២១ ការដ្ឋានការងារ សហករណ៍ និងអំពើប្រល័យពូជសាសន៍”[80]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការបំបែកសំណុំរឿង ០០២ តាមវិធីបែបនេះ “មិនត្រឹមតែស្របនឹងជំហររបស់ភាគីពីរបៀបធ្វើឱ្យវិសាលភាពនៃសំណុំរឿង ០០២/០១ មានភាពជាតំណាងសមស្រប” នៃដីកាដំណោះស្រាយប៉ុណ្ណោះទេ ប៉ុន្តែជាសត្យានុម័តបានបំពេញលក្ខខណ្ឌនានាខាងលើថាតើត្រូវកាត់បន្ថយបទចោទនា-នានៅក្នុងដីកាដំណោះស្រាយយ៉ាងដូចម្តេច[81]។បន្ទាប់ពីបានពិចារណាថា ការបំបែកកិច្ចដំណើរការនីតិវិធីសវនាការគឺជាការចាំបាច់នោះ នាពេលនេះ អង្គជំនុំជម្រះត្រូវសម្រេចថា តើការដ្ឋានការងារ និងសហករណ៍ណាខ្លះដែលគួរបញ្ចូលក្នុងសំណុំរឿង ០០២/០២ និងត្រូវពិចារណាថា តើ

---

[80] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៧៦។

[81] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៧០។

គួរបន្ថែមអង្គហេតុណាខ្លះទៀតដែរ ឬទេ ទៅក្នុងសំណុំរឿង ០០២/០២ ក្រៅពីអង្គហេតុដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល។

៣២. សំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីក គឺធ្វើឡើងស្របទៅតាមដីកាបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល ទន្ទឹមនឹងនោះអាចរក្សាបាននូវវិសាលភាពមួយដែលអាចគ្រប់គ្រងបាន ដូចបានលើកឡើងក្នុងចំណុច ៥.១.២ ខាងលើ។ ជាងនេះទៀត អង្គជំនុំជម្រះពិចារណាថា ការបន្ថែមបទចោទនានា និងទីតាំងឧក្រិដ្ឋកម្មទៅក្នុងសំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីកនោះនឹងផ្តល់គុណសម្បត្តិឆ្លើយតបទៅនឹងកង្វល់មួយចំនួនដែលបានលើកឡើងដោយមេធាវីការពារក្តី នួន ជា និង ដើមបណ្តឹងរដ្ឋប្បវេណី ហើយទន្ទឹមនឹងនោះក៏បានអនុញ្ញាតឱ្យបញ្ចប់សវនាការក្នុងថិរវេលាមួយសមស្របដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា វិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវមានទីតាំងឧក្រិដ្ឋកម្ម និងបទចោទនានាដែលមានរៀបរាប់ក្នុងសំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីក ដូចមានរៀបរាប់ខាងក្រោម។

៣៣. សំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីកបានបញ្ចូលរួចហើយនូវការចោទប្រកាន់អំពីការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ (កថាខណ្ឌ ៨៤២ ដល់ ៨៦១ នៃដីកាដំណោះស្រាយ)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំពង្រីកវិសាលភាពនៃការចោទប្រកាន់ពីការរំលោភសេពសន្ថវៈ និងការរៀបការដោយបង្ខំ នៅក្នុងក្របខណ្ឌទូទាំងប្រទេស ហើយមេធាវីការពារក្តី នួន ជា ក៏មិនបានជំទាស់ទៅនឹងសំណើនេះដែរ[82]។ ការបន្ថែមនេះនឹងតម្រូវឱ្យមានការស្តាប់សក្ខីកម្មសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីពីភូមិភាគនីមួយៗ (សរុបមានចំនួនប្រាំពីរ) និងអ្នកជំនាញមួយរូប[83]។ ដោយសារនេះជាអាទិភាពទីមួយនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណី ហើយការឯកភាពតាមសំណើតែមួយនេះនឹងនាំឱ្យមានការពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០២ តិចតួចប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើនេះមានលក្ខណៈសមហេតុផល និងសម្រេចបញ្ចូលការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងវិសាលភាពនៅទូទាំងប្រទេសក្នុងសំណុំរឿង ០០២/០២។

---

[82] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៤៤ (ភាសាអង់គ្លេស)។

[83] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១៣។

00981726



៣៤. មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យបញ្ចូលទីតាំងឧក្រិដ្ឋកម្ម និងអង្គហេតុចោទប្រកាន់បន្ថែមទៀត ជាពិសេសទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគបូព៌ា និង ភូមិភាគឧត្តរ[84]។ ទីតាំងឧក្រិដ្ឋកម្មមួយទៀតដែលមេធាវីការពារក្តី នួន ជា បានស្នើសុំគឺការដ្ឋានទំនប់ត្រពាំងថ្ម។ ទីតាំងឧក្រិដ្ឋកម្មនេះក៏ត្រូវបានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដែរដោយសារ "វាផ្តល់នូវភាពជាតំណាងភូមិសាស្ត្រសម្រាប់ភូមិភាគពាយ័ព្យ" និង "ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ [...] មានកម្រិតខ្ពស់ណាស់"[85]។ អង្គជំនុំជម្រះពិចារណាថា វាក៏ជាផលប្រយោជន៍យុត្តិធម៌ដែរ ដែលបញ្ចូលទីតាំងឧក្រិដ្ឋកម្មនេះនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

៣៥. មេធាវីការពារក្តី នួន ជា ក៏ស្នើសុំបញ្ចូលការចោទប្រកាន់ស្តីពីការបោសសម្អាតផ្ទៃក្នុង (កថាខណ្ឌ ១៩២ ដល់ ២០៣ នៃដីកាដំណោះស្រាយ) ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ (សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានស្នើសុំបែបនេះដែរ)។ ដោយសារពិចារណាថា ក្រុមមេធាវីការពារក្តី នួន ជា កំណត់ការបញ្ចូលការចោទប្រកាន់ទាំងនេះថា "មានសារៈសំខាន់បំផុត" សម្រាប់ផលប្រយោជន៍ជនជាប់ចោទ ហើយថា ការទទួលយកសំណើរនេះនឹងមិនចំណាយពេលសវនាការដែលបានគណនារួចហើយនោះច្រើនទេ អង្គជំនុំជម្រះក៏ទទួលយកសំណើសុំបញ្ចូលការចោទប្រកាន់ទាំងនេះទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ផងដែរ។ ដូចដែលនឹងពិភាក្សាខាងក្រោមបន្ថែម ការបោសសម្អាតផ្ទៃក្នុងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការចោទប្រកាន់ពីការជម្លៀសប្រជាជនដោយបង្ខំ ហើយហេតុនេះ ការបញ្ចូលការចោទប្រកាន់ទាំងនេះឆ្លុះបញ្ចាំងពីខ្លឹមសារទូលំទូលាយជាងមុននៃដីកាដំណោះស្រាយ។

៣៦. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យបន្ថែមមន្ទីរសន្តិសុខ ភូមិភាគឧត្តរ និងមន្ទីរសន្តិសុខ កោះខ្យង។ មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យបន្ថែមមន្ទីរសន្តិសុខ វត្តគិរីរម្យ ឬមន្ទីរសន្តិសុខ វត្តធ្លក។ ដីកាបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូលពុំបានតម្រូវឱ្យបញ្ចូលទីតាំងទាំងនេះទេ ដោយសារសំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីកបានបញ្ចូលមន្ទីរ ស-២១ ការដ្ឋានការងារ សហករណ៍ និងអំពើប្រល័យពូជសាសន៍[86]។ អង្គជំនុំជម្រះសាលាដំបូងប្រឈម

---

[84] ប្រតិចារឹក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ទំព័រ ៤៣ (ភាសាអង់គ្លេស)។

[85] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១៩។

[86] លើសពីនេះ អង្គជំនុំជម្រះបានជ្រើសរើសរួចហើយ ដើម្បីបញ្ចូលការដ្ឋានពីរបន្ថែមទៀត (ទំនប់ត្រពាំងថ្ម និង ព្រលានយន្តហោះកំពង់ឆ្នាំង) រួមទាំងមន្ទីរសន្តិសុខពីរបន្ថែមទៀត (មន្ទីរសន្តិសុខ អូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល)។ ចុងក្រោយ អង្គ-ជំនុំជម្រះបានបញ្ចូលការចោទប្រកាន់អង្គហេតុស្តីពីការបោសសម្អាតផ្ទៃក្នុង។

នឹងភារៈកិច្ចលំបាកនៃការរក្សាតុល្យភាពនៃកិច្ចដំណើរការនីតិវិធីមួយដើម្បីឱ្យមានប្រសិទ្ធភាព និងឆាប់រហ័ស ទន្ទឹមនឹងពេលនោះក៏ពិចារណាដល់ផលប្រយោជន៍របស់ភាគីនានាដែលបានលើកឡើង។ ការលំបាកនោះគឺថា អង្គជំនុំជម្រះមានជំនឿថា ការបញ្ចូលទីតាំងបន្ថែមទាំងនេះទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នឹងប៉ះពាល់ដល់ប្រសិទ្ធភាព និងភាពគ្រប់គ្រងបានដែលកើតឡើងដោយការជ្រើសរើសបំបែកកិច្ចដំណើរការនីតិវិធីសវនាការសំណុំរឿង ០០២ តាំងពីដំបូងម្ល៉េះ ដោយមិនបានទទួលផលប្រយោជន៍ទៅតាមអ្វីដែលភាគីចង់បាន។ សម្រាប់សំអាងហេតុទាំងនេះ អង្គជំនុំជម្រះសម្រេចមិនបញ្ចូលទីតាំងឧក្រិដ្ឋកម្ម ឬការចោទប្រកាន់បន្ថែមទាំងនេះទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ទេ។

៣៧. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានស្នើសុំឱ្យបញ្ចូលការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីបីនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែរ។ មេធាវីការពារក្តី នួន ជា យល់ស្របនឹងសំណើនេះ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំត្រូវបានយកមកជញ្ជែងយ៉ាងទូលំទូលាយរួចមកហើយក្នុងសំណុំរឿង ០០២/០១។ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីបីនឹងត្រូវលើកយកមកពិចារណាក្នុងវិសាលភាពមួយចំនួនក្នុងសំណុំរឿង ០០២/០២ តាមរយៈការបញ្ចូលមន្ទីរ ស-២១ និង ការបោសសម្អាតផ្ទៃក្នុងដែលនឹងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទីបីនេះ។ ដោយសារការចោទប្រកាន់ពីការជម្លៀសប្រជាជនត្រូវបានវិលេចក្នុងសំណុំរឿង ០០២/០១ រួចហើយនោះ អង្គជំនុំជម្រះសាលាដំបូងសម្រេចមិនបញ្ចូលការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទីបី ទៅក្នុងសំណុំរឿង ០០២/០២ ទេ។

៣៨. សំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីក លើកឡើងពីការប្រព្រឹត្តចំពោះពុទ្ធសាសនិក តាមរយៈការបញ្ចូលទីតាំងសហករណ៍ត្រាំកក់ (ដែលមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពាក់ព័ន្ធនឹងទីតាំងនោះ ដោយរួមទាំងការធ្វើទុក្ខបុកម្នេញដល់ពុទ្ធសាសនិកផង) រួមទាំងការចោទប្រកាន់ជាទូទៅនៅក្នុងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិក។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើជាបញ្ហាអាទិភាពទីពីរថា ការប្រព្រឹត្តចំពោះពុទ្ធសាសនិក គួរតែបញ្ចូលទៅក្នុងសំណុំរឿង ០០២/០២ ក្នុងក្របខណ្ឌទូទាំងប្រទេស។ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋាន ការបញ្ចូលការចោទប្រកាន់ទូទៅដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិក និង សហករណ៍ត្រាំកក់ជាឧទាហរណ៍មួយនៃទីតាំងឧក្រិដ្ឋកម្មដែលឆ្លុះបញ្ចាំង

សមស្របនូវទំហំ និងលក្ខណៈនៃអំពើនានាដែលត្រូវបានចោទប្រកាន់ ខណៈដែលបង្កើនសវនាការមួយដែលមានប្រសិទ្ធភាពចំពោះប្រធានបទនេះ។ ហេតុនេះ អង្គជំនុំជម្រះទទួលយកសំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីកត្រង់ចំណុចនេះ និងមិនពង្រីកការប្រព្រឹត្តចំពោះពុទ្ធសាសនិកនៅក្នុងវិសាលភាពទូទាំងប្រទេសទេ។

៣៩. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ពីការប៉ាន់ប្រមាណពេលវេលារបស់សហព្រះរាជអាជ្ញាដែលថា សវនាការលើអង្គហេតុនានានៅក្នុងសំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីកនោះនឹងត្រូវចំណាយពេលពីពីរទៅបីឆ្នាំទើបចប់។ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងបន្ថែមទីតាំងឧក្រិដ្ឋកម្មថែមទៀតនឹងមិនបន្ថែមពេលវេលាច្រើនទៀតដល់ការប៉ាន់ប្រមាណនេះទេ។ ទោះបីអង្គជំនុំជម្រះសាលាដំបូងមិនអាចផ្តល់ការប្រមាណច្បាស់លាស់ចំពោះថិរវេលានៃកិច្ចដំណើរការនីតិវិធីដែលនឹងត្រូវចំណាយបន្ទាប់ពីមានការបំបែកកិច្ចដំណើរការនីតិវិធីសវនាការក៏ដោយក៏អង្គជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះអាចដំណើរការសវនាការចំពោះអង្គហេតុដែលបានចោទប្រកាន់ដូចដែលបានលើកឡើងក្នុងថិរវេលាមួយដ៏សមស្របបាន។

៤០. ចំពោះសំណើរបស់ នួន ជា ពាក់ព័ន្ធនឹងលទ្ធភាពដែលអាចផ្តល់ឱ្យមេធាវីការពារក្តីក្នុងការបន្ថែមភស្តុតាងនៅពេលសវនាការវិញ អង្គជំនុំជម្រះអះអាងជាថ្មីថា វិធាន ៨៧ នៃវិធានផ្ទៃក្នុងបានបង្កើតនូវក្របខណ្ឌគតិយុត្តសម្រាប់ភាពទទួលយកបាននៃភស្តុតាងនៅពេលសវនាការ ហើយអង្គជំនុំជម្រះត្រូវតែបន្តគោរព និងអនុវត្តតាមក្របខណ្ឌនេះ[87]។

## ៥.៣ <u>កថាខណ្ឌនានាក្នុងដីកាដំណោះស្រាយ</u>

៤១. ភាគីបានលើកឡើងថា ផ្នែក និងកថាខណ្ឌមួយចំនួននៅក្នុងដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម គោលនយោបាយ សាវតា និងបរិបទប្រវត្តិសាស្ត្រ គួរតែបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ រួមទាំងកថាខណ្ឌ និងផ្នែកមួយចំនួនដែលបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ រួចហើយ[88]។ អង្គជំនុំជម្រះសូមធ្វើការពន្យល់ដូចខាងក្រោម ស្តីពីការ

---

[87] ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ (អ.ជ.ស.ដ), ឯកសារ E302/5, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤, កថាខណ្ឌ ៨។

[88] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីវិសាលភាព, កថាខណ្ឌ ១០ ដល់ ១៨, ២១; សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២, ឯកសារ E301/5/1, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤, កថាខណ្ឌ ២;

បញ្ចូលផ្នែកនិងកថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម គោល-នយោបាយ សាវតា និងបរិបទប្រវត្តិសាស្ត្រ ក្នុងសំណុំរឿង ០០២/០២ និងភ្ជាប់ឧបសម្ព័ន្ធមួយដែលបញ្ចូលកថាខណ្ឌពាក់ព័ន្ធនៃដីកាដំណោះស្រាយ។

៤២. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានស្តាប់ភស្តុតាងដែលពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយ-នីស្តកម្ពុជា រចនាសម្ព័ន្ធ ទំនាក់ទំនងរដ្ឋបាល និងយោធា គោលនយោបាយសហឧក្រិដ្ឋកម្មរួម និងតួនាទី និងអត្តចរិតរបស់ជនជាប់ចោទ[89]។ ភស្តុតាងដែលបានដេញដោលនេះក្លាយជាមូលដ្ឋានគ្រឹះសម្រាប់សវនាការលើអង្គហេតុនានាដែលនៅសេសសល់ក្នុងសំណុំរឿង ០០២[90]។ ទោះជាយ៉ាងណាក្តី បញ្ហាមួយចំនួនដែលបានលើកឡើងខាងលើនេះមិនត្រូវបានយកមកពិនិត្យយ៉ាងពេញលេញក្នុងសំណុំរឿង ០០២/០១ ទេ ដោយសារវិសាលភាពរបស់វាមានកំរិត ហើយអាចនឹងពាក់ព័ន្ធក្នុងបរិបទនៃសំណុំរឿង ០០២/០២ ដែរ[91]។ ហេតុនេះ ផ្នែកទាំងនេះនៃដីកាដំណោះស្រាយត្រូវបានបញ្ចូលយ៉ាងទូលំទូលាយទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដោយសារផ្នែកទាំងនេះមាន

---

សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤, កថាខណ្ឌ ៨ ដល់ ៣៧; ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ៧។

[89] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163), ឯកសារ E124/7.3, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២។

[90] ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ (អ.ជ.ស.ដ), ឯកសារ E302/5, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤, កថាខណ្ឌ ៥, ៧។

[91] ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ (អ.ជ.ស.ដ), ឯកសារ E302/5, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤, កថាខណ្ឌ ៨; *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និង សំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ឯកសារ E124/7, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, កថាខណ្ឌ ១១ (ដោយកត់សម្គាល់ថាអង្គជំនុំជម្រះនឹងផ្តល់នូវការពិចារណាលើអង្គហេតុពិស្តារក្នុងសវនាការលើកដំបូង ចំពោះបទចោទទាំងនោះដែលត្រូវបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១); ការឆ្លើយតបទៅនឹងបញ្ហានានាដែលភាគីបានលើកឡើងមុនពេលសវនាការ និងការកំណត់កាលបរិច្ឆេទនៃការប្រជុំជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ដ), ឯកសារ E141, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ២។

ការចោទប្រកាន់អង្គហេតុដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ នេះ ហើយមិនធ្លាប់ត្រូវបានយកមកពិនិត្យពីពេលមុន ឬមិនត្រូវយកមកពិនិត្យឱ្យបានពេញលេញនៅឡើយ។

៤៣. ដោយឡែក អង្គជំនុំជម្រះកត់សម្គាល់ថា ការផ្លាស់ទីលំនៅជនជាតិភាគតិចចាមបង្កើតជាមូលដ្ឋាននៃការចោទប្រកាន់ស្ដីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា រួមទាំងជាមធ្យោបាយមួយនៃការអនុវត្តគោលនយោបាយដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីពីរ) និងការប្រព្រឹត្តិចំពោះក្រុមដែលក្លាយជាគោលដៅ[92]។ អង្គជំនុំជម្រះបានដកនូវអង្គហេតុនៃការចោទប្រកាន់ទាំងនេះចេញ ដោយផ្អែកលើគោលនយោបាយដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម រួមទាំងអង្គហេតុស្ដីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា ចេញពីវិសាល-ភាពនៃសំណុំរឿង ០០២/០១[93]។ ទោះជាយ៉ាងណាក្ដី ការប្រព្រឹត្តចំពោះជនជាតិចាម និងអង្គហេតុស្ដីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនារួមទាំងក្នុងដំណើរការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីពីរ) ត្រូវបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ហេតុនេះ អង្គជំនុំជម្រះក៏បានបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែរ នូវគោលនយោបាយស្ដីពីការផ្លាស់ទីលំនៅប្រជាជនប៉ុណ្ណោះ ដោយសារដីកាដំណោះស្រាយចោទប្រកាន់ថាគោលនយោបាយនេះត្រូវបានយកមកអនុវត្តតាមរយៈការផ្លាស់ទីលំនៅជនជាតិភាគតិចចាម។

៤៤. ជាចុងក្រោយ អង្គជំនុំជម្រះបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នូវការអនុវត្តគោលនយោបាយនៃការចាត់ទុកជាគោលដៅនូវអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ តាមរយៈការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ[94]។ វិសាលភាពនៃសំណុំរឿង០០២/០២ រួមមាន *ក្នុងចំណោម*

---

[92] ដីកាដំណោះស្រាយ, កថាខណ្ឌ២៦៦, ២៦៨, ២៨១, ៩០១, ១៤២០, ១៤៦៨។

[93] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១, ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធិ ក្នុងការចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163), ឯកសារ E124/7.3, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២។

[94] ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១, ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធិ ក្នុងការចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163), ឯកសារ E124/7.3, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២; សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែក

*នោះ* សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១-មករា មន្ទីរសន្តិសុខ ស-២១ និង មន្ទីរសន្តិសុខ ក្រាំងតាចាន់។ ការចោទប្រកាន់អង្គហេតុដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗពាក់ព័ន្ធនឹងគោលនយោបាយនៃការចាត់ទុកជាគោលដៅនូវអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ[95]។ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយប្រឆាំងនឹងអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរក៏ត្រូវបានចោទប្រកាន់ផងដែរ ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗនៃទីតាំងឧក្រិដ្ឋកម្មទាំងបួន[96]។ ហេតុនេះ អង្គជំនុំជម្រះបានបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នូវគោលនយោបាយពាក់ព័ន្ធនឹងការចាត់ទុកជាគោលដៅនូវអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ កំណត់ត្រឹមតែការអនុវត្ត នៅសហករណ៍នានានៅត្រាំកក់ ការដ្ឋានទំនប់ ១-មករា មន្ទីរសន្តិសុខ ស-២១ និង មន្ទីរសន្តិសុខក្រាំងតាចាន់។

## ៥.៤ ស្ថានភាពនៃបទចោទនានាដែលនៅសេសសល់

៤៥. ការបំបែកកិច្ចដំណើរការនីតិវិធីសវនាការដែលបានលើកឡើងខាងលើមិនរាប់បញ្ចូលនូវអង្គហេតុបទចោទ និង ទីតាំងឧក្រិដ្ឋកម្មមួយចំនួនទៅក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ក្របខណ្ឌគតិយុត្តនៅ អ.វ.ត.ក ពុំបានដកចេញនូវលទ្ធភាពនៃការដកចេញនូវបទចោទមួយចំនួន ទេ[97]។ ក្នុងន័យនេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ពីកង្វល់របស់មេធាវីការពារក្តី នួន ជា ដែលថា "សេចក្តីសម្រេចដក ឬលើកលែងបទចោទនានាពុំមានយុត្តិសាស្ត្រច្បាស់លាស់ទាំងនៅក្នុងនីតិវិធីនៃតុលាការថ្នាក់ជាតិ ឬអន្តរជាតិ"[98]។ ទោះជាយ៉ាងណាក្តី ដោយសារតែអង្គជំនុំជម្រះសាលាដំបូងមិនទាន់បានទទួលសំណើណាមួយពីសហព្រះរាជអាជ្ញា

---

កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និង សំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ឯកសារ E124/7, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, កថាខណ្ឌ ១១; ការឆ្លើយតបទៅនឹងបញ្ហានានាដែលភាគីបានលើកឡើងមុនពេលសវនាការ និងការកំណត់កាលបរិច្ឆេទនៃការប្រជុំជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (អ.ជ.ស.ដ), ឯកសារ E141, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ២។

[95] ដីកាដំណោះស្រាយបានចោទប្រកាន់ថា មានគំរូស្តីពីការកំណត់ជាគោលដៅទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ ការចោទប្រកាន់លើអង្គហេតុដែលពាក់ព័ន្ធនឹងគំរូនេះត្រូវបានបញ្ចូលក្នុងផ្នែកនៃដីកាសំណោះស្រាយដែលពាក់ព័ន្ធនឹងសហករណ៍នៅត្រាំកក់ (ដីកាដំណោះស្រាយ, កថាខណ្ឌ ៣១៩) ការដ្ឋានទំនប់ ១ មករា (ដីកាដំណោះស្រាយ, កថាខណ្ឌ ៣៦៦) មន្ទីរសន្តិសុខ ស-២១ (ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៣២) មន្ទីរសន្តិសុខក្រាំងតាចាន់ (ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៩៨, ៥០០)។

[96] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤១៦ ដល់ ១៤១៨។

[97] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់ អ.ជ.ត.ក, កថាខណ្ឌ ៦១ ដល់ ៦២។

[98] ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ១២។

ដែលសុំដកបទចោទនានាចេញពីដីកាដំណោះស្រាយនោះ[99] អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ដោះស្រាយបញ្ហានេះនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះទេ។

## ៥.៥ នីតិវិធីបន្តបន្ទាប់ក្នុងសំណុំរឿង ០០២/០២

៤៦. ដោយបានកំណត់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ នាពេលនេះ ភាគីត្រូវបានអញ្ជើញឱ្យដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងបញ្ជីឯកសារផង។ ក្នុងន័យនេះ អង្គជំនុំជម្រះសាលាដំបូងនឹងចេញដីកាបង្គាប់ដោយឡែកមួយ[100]។ បន្ទាប់មក ដូចដែលបានចង្អុលបង្ហាញក្នុងផែនការការងាររបស់ខ្លួនសម្រាប់សំណុំរឿង ០០២/០២ ដែលបានចេញក្នុងខែ ធ្នូ ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់ពេលសវនាការបឋមសម្រាប់សំណុំរឿង ០០២/០២។ អង្គជំនុំជម្រះបន្តពិចារណាដល់កម្មវត្ថុនៃរឿងក្តីនានាដែលពាក់ព័ន្ធចាំបាច់ដែលត្រូវដោះស្រាយ មុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលលើភស្តុតាងក្នុងសំណុំរឿង០០២/០២។ នៅពេលដែលបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដាក់ភ្លាម អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាកំណត់អាទិភាពនៃប្រធានបទក្នុងសំណុំរឿង ០០២/០២ ភ្លាម។

**តាមសំអាងហេតុដូចដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូង ÷**

**សម្រេចទទួលយក** សំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង **សម្រេចបំបែក** កិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿងក្តីនេះ អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង។

---

[99] សហព្រះរាជអាជ្ញាមិនបានស្នើសុំដកអង្គហេតុណាមួយពីដីកាដំណោះស្រាយទេ ផ្ទុយទៅវិញបានស្នើ "សុំកំណត់ភស្តុតាងដែលត្រូវយកមកបង្ហាញចំពោះការចោទប្រកាន់អង្គហេតុនីមួយ ដោយដកចេញនូវព្រឹត្តិការណ៍ និងទីតាំងឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនពីសវនាការ [សំណុំរឿង ០០២/០២]"។ *សូមមើល* សេចក្តីសន្និដ្ឋានរបស់ ក.ស.ព លើវិសាលភាព, កថាខណ្ឌ ២៦។

[100] អង្គជំនុំជម្រះកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានដាក់បញ្ជីឈ្មោះបឋមនៃសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០២/០២ ដោយផ្អែកលើសំណើសុំរបស់ ក.ស.ព ដែលត្រូវបានពង្រីកបន្ថែម។ ទោះជាយ៉ាងណាក្តី ពេលនោះ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា "បញ្ជីឈ្មោះទាំងនោះកំពុងត្រូវបានពិនិត្យមើល និងវាយតម្លៃឡើងវិញ ហើយសហព្រះរាជអាជ្ញានឹងដាក់បញ្ជីឈ្មោះសាក្សីចុងក្រោយបន្ទាប់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវបានសម្រេចរួច និងនៅពេលដែលអង្គជំនុំជម្រះកំណត់កាលបរិច្ឆេទសម្រាប់ឱ្យភាគីទាំងអស់ដាក់បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ និងឯកសារនានា")។ ផែនការសវនាការសំណុំរឿង ០០២/០២ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា (ជាមួយឧបសម្ព័ន្ធសម្ងាត់ ក), ឯកសារ E301/2/1, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៣, កថាខណ្ឌ ១។

00981733



**សម្រេចទទួលយក** សំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយផ្នែក និង ដោយអនុលោមតាមដីកាបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ **សម្រេចថា** វិសាលភាពនៃសំណុំរឿង ០០២/០២ រួមមានផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ ការដ្ឋានទំនប់ ១-មករា សហករណ៍ត្រាំកក់ និង អំពើប្រល័យពូជសាសន៍ (ចំពោះជនជាតិវៀតណាម និង ជនជាតិចាម)។

**សម្រេចទទួលយក** សំណើរបស់សហព្រះរាជអាជ្ញា សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សំណើរបស់មេធាវីការពារក្តី នួន ជា មួយផ្នែក និង **សម្រេច** បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នូវមន្ទីរសន្តិសុខ ក្រាំងតាចាន់ ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ អូរកន្សែង មន្ទីរសន្តិសុខ ភ្នំក្រោល ការដ្ឋានទំនប់ត្រពាំងថ្ម និង ការចោទប្រកាន់ស្តីពីការរៀបការដោយបង្ខំ និងរំលោភសេពសន្ថវៈ (ក្នុងក្របខណ្ឌទូទាំងប្រទេស) និង ការបោសសម្អាតផ្ទៃក្នុង។

**សម្រេចបដិសេធ** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នូវមន្ទីរសន្តិសុខ ភូមិភាគឧត្តរ មន្ទីរសន្តិសុខ កោះខ្យង និងផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីបី និងសុំពង្រីកការចោទប្រកាន់អង្គហេតុនានាដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិកក្នុងវិសាលភាពភូមិសាស្ត្រនៅទូទាំងប្រទេស។

**សម្រេចបដិសេធ** សំណើរបស់មេធាវីការពារក្តី នួន ជា ដែលសុំបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នូវការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីបី និង មន្ទីរសន្តិសុខ វត្តគិរីរម្យ ឬ មន្ទីរសន្តិសុខ វត្តធ្លក។

**សម្រេច** មិនពិចារណាសម្រេចនៅពេលនេះចំពោះបទចោទនានាដែលមិនបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ០០២/០២ ហើយអង្គជំនុំជម្រះនឹងលើកយកបញ្ហានេះមកដោះស្រាយនៅក្នុងពេលវេលាសមស្រប។

**ភ្ជាប់** ឧបសម្ព័ន្ធ "ក" ដែលរួមមានបញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ដែលបង្កើតជាផ្នែកនៃសេចក្តីសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**